# ការសំភាសន៍ជាលើកទី២របស់លោកពូ ឡាយ ផល្លី

**កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា　　　　ខៈ អ្នកដែលត្រូវគេសំភាសន៍ ឡាយ ផល្លី**

## ជីវប្រវត្តិសង្ខេបជាលើកទី២របស់លោកពូ ឡាយ ផល្លី

នៅក្នុងការសំភាសន៍ជាលើកទី២ លោកពូបានប្រាប់ពីជីវិតរបស់គាត់ដ៏សែនជូរចត់ក្នុងសម័យសម័យសង្គ្រាមហើយនឹងបន្ទាប់ពីសង្គ្រាម។ លោកពូត្រូវបានគេយកទៅលត់ដំតែដំបូងគិតទំនងគឺថាយកទៅសម្លាប់ចោលទេ គឺពូតែងតែទន្ទេញថាពេលគេចាប់ទៅគឺយកទៅកោះគរ ហើយកោះគរគឺជាទីកន្លែងមួយដែលពួកប៉ុល ពតយកមនុស្សយកទៅសម្លាប់ចោល គឺមានរណ្ដៅសាកសពនៅទីនោះ!!ហើយដោយសារដើរបណ្ដើរយកទៅហ្នឹងមិនបានទៅជួបមេកងធំដែលគេហៅថាសាម៉ាក់មិត្តបង ដូច្នេះក៏គេអោយគាត់កាប់ដីនៅទីដែលគេនាំយកគាត់ទៅទៅ គឺធ្វើការដ៏ខ្លាំងបំផុត។ បន្ទាប់បីរបរប៉ុល ពតលោកពូបានធ្វើជាទាហានហើយទៅវ៉ៃនៅបរប៉ៃលិន ហើយលោកពូបាននាំមិត្តភក្តិមកពេទ្យគេថាលោកពូបានបាស់បោរអោយទាហានបាក់ទ័ពតែវាមិនមែនទេ ហើយគាត់មិនត្រលប់ទៅធ្វើទាហាននៅទីហ្នឹងទៀតព្រោះឮគេថាបើទៅគេនឹងចាប់បាញ់សម្លាប់។លោកពូក៏ធ្លាប់បានទៅធ្វើការនៅប្រទេសថៃដែរហើយដោយសារការជំពាក់បំណុលទើបគាត់បង្ខំចិត្តទៅតែធ្វើការគាត់ថាមិនពិបាកប៉ុន្មានទេ។ឥឡូវលោកពូបានត្រលប់មកពីថៃវិញហើយបានរស់នៅជាមួយក្រុមគ្រួសារ។លែងទៅធ្វើការនៅប្រទេសថៃទៀត ។

កៈ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់លោកពូផល្លីដើម្បអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់លោកពូម្ដងទៀត នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាសំភាសន៍អំពីនៅក្នុងថ្ងៃនេះ ថ្ងៃពួកយើងសំភាសន៍គឺនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៨ ការសំភាសន៍ស្ថិតនៅក្នុងភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្ត កណ្ដាល ប្រទេសកម្ពុជា  អ៊ីចឹងពួកយើងនឹងចាប់ផ្ដើមសំភាសន៍អំពីជីវប្រវត្តិរបស់លោកពូបន្ថែមទៀតនូវអ្វីដែលលោកពូបានអត់ទាន់រៀបរាប់ប្រាប់នឹងទុកចង់អោយកូនចៅគាត់ស្ដាប់នៅពេលក្រោយៗទៀតនឹងសំរាប់ពិភពលោកទាំងមូលដើម្បីចង់ដឹងប្រវត្តិរបស់ប្រជាជនកម្ពុជាយើង អ៊ីចឹងលោកពូសូមប្រាប់ឈ្មោះពេញម្ដងទៀត?

ខៈ ឈ្មោះពេញឈ្មោះឡាយ ផល្លីហ្នឹងដដែលហ្នឹង។

ក៖ចាំហ្នឹងហើយ!! អ៊ីចឹងលោកពូសំរាប់ ចូលដល់ការសិក្សារបស់លោកពូវិញពូបានរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

ខ៖ បើ គិតជារៀនយើងរាប់ពីមុនមកឥឡូវវារាប់បញ្ច្រាស់គ្នាណាស់ ប៉ុនថាចឺបានរាប់បញ្ច្រាស់យើងពីមុន ដល់យើងនិយាយពីឥឡូវវិញនិយាយពីឥឡូវមុន ពីឥឡូវយើងរាប់ពីថ្នាក់ទី១ទី២ទៅ ហើយកាលពីជំនាន់ញ៉ុមនឹងរាប់ពីលើចុះមកក្រោមវិញ។កះចាំ!!ខ៖រាប់ពីថ្នាក់ទី១២ចុះមកវិញហើយកាលហ្នឹងជំនាន់ដែលញ៉ុមរៀនចូលអាគេហៅថ្នាក់មត្តេយ្យថ្នាក់ទីមួយដំបូងហ្នឹងថ្នាក់ទី១២។កះចាំ!!ខ៖ហើយថ្នាក់ទី១២ហើយដល់ខ្ញុំបានរៀនដល់ត្រឹមញ៉ុមឈប់រៀនដល់សម័យសង្គ្រាមហ្នឹង សម័យសង្គ្រាមហ្នឹងញ៉ុមរៀនដល់៧៥(១៩៧៥)ខ្ញុំរៀនបានច្រើនដែរ តែខ្ញុំរៀនមកដល់ត្រឹមឆ្នាំ៧៣(១៩៧៣)ដល់ឆ្នាំ៧៣(១៩៧៣)ហ្នឹងខ្ញុំរៀនបានមកដល់ថ្នាក់ទី៧ ថ្នាក់ទី៧ជំនាន់ញ៉ុមរៀនហ្នឹងរៀន រៀនបារាំងហើយចេះ ចេះបារាំងរូហើយ ។

ក៖ពូចេះច្រើនទេអ៊ីចឹង?

ខ៖ឥឡូវហ្នឹងនៅចាំខ្លះៗហើយក៏នៅដាក់ឈ្មោះបានខ្លះៗដែរ តែគ្រាន់តែថាពាក្យជ្រៅដូចថាមុនដូចថាពាក្យបារាំងហ្នឹងដូចថា យើងអានឈ្មោះអីយើងបកប្រែបានអ៊ីចឹងហាំ!!ដល់ឥឡូវញ៉ុមខានរៀនយូរញ៉ុមភ្លេចអស់ហើយ ដល់ឥឡូវរៀនសៀវភៅជាបារាំងមកញ៉ុមអាមើលរួចខ្លះៗ។កះហ៊ុៗ!!ខ៖ហើយបើថាដល់និយាយអ៊ីចឹងរាល់ថ្ងៃអាកូនគេរៀនហ្នឹង ដល់យើងវាអានបារាំងអញ្ចេះវាថាមិនមែនទេ គេអានអង់គ្លេស មួយអង់គ្លេសគេអានបារាំងវាខុស ហើយដល់អង់គ្លេសយើងអត់ចេះ។កះចាំ!!ខ៖បាទវាអ៊ីចឹងដល់អ៊ីចឹងវាបញ្ច្រាស់គ្នាអ៊ីចឹង ដល់អ៊ីចឹងមិនដឹងថាម៉េច!!!

ក៖អ៊ីចឹងពូរៀនបានដល់ថ្នាក់ទី៧?

ខ៖បាទ!!

ក៖មូលហេតុអីបានពូឈប់រៀនដោយសារសង្គ្រាមឬក៏ម៉េចពូ?

ខ៖កាលហ្នឹងមកដល់សម័យសង្គ្រាម សម័យសង្គ្រាមតែឪពុកញ៉ុមហ្នឹងចង់អោយកូនបន្តទៀតដែរដល់វានៅតំបន់កន្លែងហ្នឹងវានៅប្រទាញប្រទង់គ្នា ខ្មែរក្រហមវានៅប្រទាញប្រទង់ម្តងមួយថ្ងៃកាត់មួយថ្ងៃកោរវាវៃជាមួយលន់ នល់ហ្នំ!! ដល់នេះក៏បងញ៉ុមដែលធ្វើដុកទ័រពេទ្យនោះគាត់ថាហ៊ុំអញ្ចឹងហ្អែងទៅនៅភ្នំពេញទៀតទៅទៅរៀននៅភ្នំពេញជាមួយអញគាត់ធ្វើពេទ្យហើយ

ហើយហា៎!!ក៖ហុី!!ខ៖អោយទៅរៀននៅភ្នំពេញ ដល់ទៅរៀន ទៅមុនដំបូងទៅជាមួយគាត់ទៅសុំសាលាគេអត់បានរៀនទេទៅកន្លែងណាក៏អត់បានរៀន យើងពាក់កណ្តាលឆ្នាំចេះតែសុំអត់បានសៀវភៅអីហើយពីមុនអាពីមុនហើយឥឡូវអាសៀវភៅគេសិក្សាខៀវរិកអាសៀវភៅតាមដានហ្នឹង គេហៅសៀវភៅលីវរើរេ។ក៖ចា៎!ខ៖ជំនាន់ខ្ញុំគេហៅសៀវភៅលីវរើរ ដល់តែនេះយកទៅកន្លែងណាក៏អត់បាន យកទៅអត់បាន បងជីដូនមួយញ៉ុមមួយ ញ៉ុមនិយាយម៉ិញបើកឡានពេទ្យសម្តពក្រុងហ្នឹងកាលហ្នឹងគាត់អត់ទាន់បើកឡានពេទ្យទេគាត់នៅស៊ីឈ្នួលបើកឡានដឹកឈើអោយថៅកែយើងនៅចាក់អង្រែ ចាក់អង្រែលើកន្លែងមេភ្លើងចាក់អង្រែហ្នឹង ហើយដល់នេះរួចទៅគាត់មានបងថ្លៃស្រីមួយធ្វើអ្នកគ្រូបង្រៀន ដល់ទៅសុំអ្នកគ្រូហ្នឹងបង្រៀនបានចូលរៀន រៀនហ្នឹងដេកនៅចាក់អង្រែ ចាក់អង្រែយើងនៅមេភ្លើងយើងនេះទេ ដល់ទៅរៀន បើនិយាយប្រាប់បែបអ្នកគ្រូមិនស្គាល់ទេសាលាហ្នឹង!!!

ក៖នៅឯណាវិញពូ?

ខ៖គេហៅសាលាថៅពញាហុកហា៎!!ស្គាល់អត់?

ក៖នៅភ្នំពេញពូហេ??

ខ៖នៅភ្នំពេញ ចាំមើលសាលាថៅពញាហុកហ្នឹងដល់ទៅដល់អព្វោកយើងឆ្លងផ្លូវចំការមនយើងទៅត្រង់ឆ្លងទៅទៅពីក្បាលថ្នល់ត្រង់ទៅអញ្ចឹងទៅដល់ទៅដល់ឆ្លងភ្លើងស្តុបចំការមនទៅទៀតដល់ទៅដល់នេះទៅដល់វិមានឯករាជ្យបត់ឆ្វេងអញ្ចេះនៅអាកាច់ជ្រុងបត់ឆ្វេងអញ្ចេះអាហ្នឹងសាលាហ្នឹងធំណាស់ពីដើមហៅសាលាថៅពញាហុកតែឥឡូវយកធ្វើជាស្អីទេឥឡូវហ្នឹង។

ក៖ញ៉ុមស្គាល់ហើយ។ខ៖បាទ!!ក៖នៅជិតវិមានឯករាជ្យដែរពូហ៎?

ខ៖គ្រាន់តែដល់វិមានឯករាជ្យបត់ឆ្វេងហា៎!!

ក៖ហុីហ្នឹងហើយស្គាល់ហើយ។

ខ៖ហ្នឹងអាហ្នឹងសាលាញ៉ុមរៀនហើយហ្នឹង។

ក៖ញ៉ុមគិតថាដូចនៅឈ្មោះដដែលទេពូ។

ខ៖សាលាហ្នឹងកាលជំនាន់ញ៉ុមរៀនគេហៅសាលាថៅពញាហុក។

កះហ្នឹងហើយញ៉ុមដូចឃើញផ្លាកឈ្មោះដដែលទេ ។

ខះខ្លះគេហៅកន្លែងហ្នឹងគេហៅបឹងកេងកង។

កះចាំហ្នឹងហើយ។ខះបាទ!!កះហ្នឹងហើយនៅតែដដែលហ្នឹងមិនស្រួលហ្ហ៎!!អ៊ីចឹងលោកពូកាលពេលរៀនហ្នឹងពូរៀននៅសាលាឈ្មោះចៅពញាហុកហ្នឹង?ខះបាទបាទ!!កះបឋមសិក្សា រៀនតែមួយសាលាហ្នឹងឬក៏២សាលា?

ខះញ៉ុមកាលយើងកាលពីដែលមុនអើរទៅរៀនហ្នឹងញ៉ុមនៅរៀនយើងនៅរៀនសាលាឈូងលៀបនេះ។កះចាំ!ខះបាទហើយដល់ទៅរៀនណោះហើយសាលាហ្នឹងទៅរៀនមួយថ្ងៃ២ពេលហ្ហ៎!!សាលាហ្នឹង!!កះហ្ហ៎!!ខះបើគិតទៅគេរៀន៣ពេលតែយើងរៀនតែពីរទេវាដូចថាចូលវាចេញដូចម៉ោង១០ចេញម៉ោង១០ចូលម៉ោង២ចេញម៉ោង២ ម៉ោង២ចេញម៉ោង៥។

កះហើយចុះម៉េចបានពីរបីពេលម្លេះ?

ខះបើគ្រូគេបង្រៀនអញ្ចឹងយើងមិនដឹងដែរ។

កះតែគ្រូ តែពូត្រូវរៀន៣ពេលដែរអត់?

ខះខ្ញុំរៀនតែ២ពេលទេ។

កះព្រឹកល្ងាចអីវ៉ាន់អញ្ចឹងទៅ?ខះបាទ!!កះតែអ្នកខ្លះរៀន៣ពេល?ខះបាទ!!កះហ្ហ៎!!!

ខះហើយកាលហ្នឹងដូចជីវភាពដូចថាម៉ែឪគាត់ផ្តល់លុយអោយមកអោយដែរតែដូចថាគាត់អាងថាបងជីដូនមួយញ៉ុមនៅហ្នឹងញ៉ុមកាលចេញពីរៀនមកអញ្ចឹងទៅអើរបើគាត់ចេញពីធ្វើការដឹកឈើអោយគេមុនម៉ោងគាត់ទៅឈប់ចាំនៅយកខ្ញុំមកផ្ទះមកហើយថ្ងៃណាគាត់ដឹកឈើអោយគេក្រមកយើងកាលជំនាន់ហ្នឹងលុយវាពិបាករកដែរលុយថ្លៃដែរដល់អញ្ចឹងខ្ញុំពីជូនកាលមានឡានគេជិះមកដល់មកដល់ផ្ទះយើងអញ្ចឹងដែរតែយើងអត់មានលុយជិះហាំ!!អញ្ចឹងញ៉ុមដើរពីសាលាចៅពញាហុកមកដល់ចាក់អង្រែហាដល់មេភ្លើង អាមេភ្លើងយើងចាក់អង្រែសាលា!!

កះឆ្ងាយពូ?។

ខះអើរអ្នកគ្រូដឹងហើយតាំងពីសាលាមកដល់ចាក់អង្រែ មិនមែនចាក់អង្រែលើទេ ចាក់អង្រែក្រោមណោះទៀត!!!

កះហ្នឹងហើយឆ្ងាយ!!

ខះញ៉ុមដើរមកហាញ៉ុមប្រាប់អ្នកគ្រូនិយាយតាមត្រង់ហ៊ិ!!

កះចា៎!!ហើយនៅពីក្មេងរឹតតែឆ្ងាយទៀតហើយ!!

ខះបាទ កាលហ្នឹងជំនាន់ហ្នឹងខ្ញុំទៅរៀនខ្ញុំអាយុប្រហែលជាខ្ទង់ ១៣ ១៤ឆ្នាំហ្នឹង។កះចា៎ៗ!ខះហើយខ្ញុំដើរគិតមើលខ្ញុំដើរមកដល់ភ្លើងស្តុបហ្នឹងមានគេដើរកាលសម័យមុនវាអត់មានឡានម៉ូតូច្រើនដូចយើងសម័យឥឡូវទេណាស់!!ដល់អានឹងចាំឈរមើលគេអោយតែឃើញភ្លើងស្តុបចាំដល់គេឈប់ឈប់ចាំដល់គេឆ្លងឆ្លងដូចគេអញ្ជឹងទៅដើរបើថាចេញមកពីសាលាម៉ោង១០ទំរាំដើរចុះយើងពីក្មេងដូចអ្នកគ្រូនិយាយអ៊ីចឹងថាយើងដើរយូរ!!កះចា៎!!ខះទំរាំមកដល់ ទំរាំមកដល់ផ្ទះ ដល់ណេះម៉ោង១ ម៉ោង២ថ្ងៃហើយដល់បងញ៉ុមណេះគេចេញមកគាត់បើកឡានដើររក រកអត់ឃើញ រកអត់ឃើញ គាត់មកដល់ផ្ទះទំរាំគាត់មកដល់ផ្ទះម៉ោង២ ម៉ោង៣ដែរ ទំរាំញ៉ុមមកផ្ទះនេះ ដល់អាអូនហ្អែងមកដល់តាំងពីរថ្មើរណា?ញ៉ុមថាញ៉ុមមកដើរ ចុះឯងម៉េចមិនចាំអញមកចូលយក !!ចាំណាបងឯងយូរពេកដើរ ដើរហត់ ដើរញើកណាស់អ្នកគ្រូញ៉ុមប្រាប់ហា!! កះចា៎!!ខះបានថាអាហ្នឹងឆាកជីវិតបានថាជីវិតញ៉ុមរៀនសូត្រខ្ញុំដើរតែរហូត ឈូងលៀបនេះក៏អញ្ជឹងដែរខ្ញុំមិនដែលមានម៉ូតូកង់ជិះអីទេតែដើរញ៉ុមប្រាប់អ្នកគ្រូតាមត្រង់ មិនមែនដូចសម័យឥឡូវកូនញ៉ុមមានកង់ជិះ គេសុទ្ធតែថាអញ្ចេះអញ្ចុះគេចង់រកម៉ូតូ!!

កះទារម៉ូតូ។

ខះរកឡានគេអីអ៊ីចឹង។

កះអត់អាចបានទាន់អញ្ជឹងទេ!!ខះបាទ!!កះអោយខំប្រឹងរៀនពីឥឡូវថ្ងៃក្រោយនឹងបានហើយ!!

ខះអ៊ីចឹងបាននិយាយបណ្តុះបណ្តាលវាថាអោយរៀនខំប្រឹង ខំប្រឹងម៉ែឪរាល់ថ្ងៃអត់ចង់បានអីពីកូនទេ ចង់អោយ អត់មានអីចែកអោយវាទេ មានតែចំនេះវិជ្ជាដែលចែកអោយវាគេហៅថាដូចថាចង់និយាយថាគ្រួសារញ៉ុមក៏អញ្ជឹងញ៉ុមក៏អញ្ជឹង ដូចថាម៉ែឪរៀនបានប៉ុណ្ណឹងដែរដូចនៅធ្វើអីមិនកើតអ៊ីចឹងចង់អោយវាហ្នឹងបង្រៀនវាហ្នឹងអោយបានលើយើងតិចទៀតទៅ។

កះហ៊ីៗ!!ចា៎លោកពូ!!

ខ៖ទោះបីវាឧបមាថាមិនបានធ្វើការងារក៏ដោយ ដូចអាមួយធំមួយនោះក៏ដោយបើអត់បានការងារម៉េចក៏ដោយអោយតែយើងបានប្រលងបាក់ឌុបសិនទៅ។ក៖ចា៎!!ខ៖ធ្លាក់ជាប់អីអោយតែយើងបានប្រលងសិនទៅបើមិនដឹងយ៉ាងម៉េចយ៉ាងម៉េចទេ ហើយ!!

ក៖អត់ទេ!!

ខ៖តែបើវាប្រលងជាប់ទៅឧបមាថាប្រលងបាក់ឌុបជាប់ខ្លាចតែវាគ្មានលុយតអោយវារៀនទៅមុខយ៉ាងម៉េចទៀតទេខ្ញុំ។

ក៖អោយតែពូកែពូ អាហាររូបករណ៍ខ្វះអី អោយប្រលងចូល។

ខ៖បានថាហ្ហ៎!!

ក៖ចុះលោកពូពេលនៅកំពុងរៀនហ្នឹងគោលបំណងដែលពូចង់ធំឡើងពូចង់ធ្វើអីគេវិញ?

ខ៖ញ៉ុមអត់មានអាចសន្និដ្ឋានរឿង រឿងថាធ្វើអីកើតញ៉ុមអត់ទាន់ដឹងគោលដៅ ព្រោះថាកាលហ្នឹងញ៉ុមរៀនដូចថា អារឿងថាធ្វើការងារហ្នឹងមិនទាន់ហ៊ានថាអើរសន្មតខ្លួនឯងថាធ្វើអីទេ ព្រោះយើងថាក្មេងយើងអត់ទាន់គិតបានថាទៅអញ្ចឹងហា៎!!

ក៖អត់ដែលស្រម៉ៃទេអញ្ចឹតងហេ??

ខ៖បាទអត់ដែលស្រម៉ៃ យើងនឹកឃើញកាលជំនាន់ញ៉ុមរៀន នឹកឃើញស្រលាញ់តែការសិក្សាហ្នឹងម៉ង!ក៖ហ៊ុៗ!!ខ៖តល្ងូវញ៉ុមចាស់ប៉ុណ្ណឹងហើយក៏ដោយបើនិយាយណែនាំកូនរាល់ថ្ងៃតើស្តាយសិក្សាញ៉ុមនូវតែនិយាយតែស្តាយការសិក្សា ខ្ញុំ ខ្ញុំប្រាប់អ្នកគ្រូហាខ្ញុំអាយុជិត៦០ប៉ុណេះហើយហារឿងលេខចំណោតអីថាធ្វើពីធរណីមាត្រអី ផ្ទៃដីក្រឡាអីញ៉ុមនៅចាំទាំងអស់ មេរៀនរបស់វាហ្នឹងញ៉ុមនៅចាំទាំងអស់មេរៀនមិនភ្លេច ជូនកាលកូន កូនវាធ្វើអត់ចេញ អត់ចេញវាមកដល់វាអោយម៉ែ ម៉ែម៉ែធ្វើអោយញ៉ុមបន្តិច ម៉ែវា អញមិនដឹងទេហ្អែងទៅសួរប៉ាហ្អែងទៅ ហើយមានតែខ្ញុំទេអាចពុះពារធ្វើអោយវាធ្វើចេញទៅ។ក៖ចា៎!!ខ៖អញ្ចឹងបានថាកិច្ចការទាំងអស់ហ្នឹងញ៉ុមនៅចាំទាំងអស់ អត់ភ្លេចទាំងអស់អ៊ីចឹងបានថាចំនេះវិជ្ជាញ៉ុមនៅស្តាយអញ្ចឹងញ៉ុមចង់និយាយរាល់ថ្ងៃញ៉ុមចង់បណ្តុះកូនអោយបានលើម៉ែឪបន្តិចទៀត!!ក៖ចា៎!!ខ៖ញ៉ុមចង់និយាយអ៊ីចឹងហិ!!តែខ្លាចគេ យើងបណ្តុះអញ្ចឹងខ្លាចគេវាមិនបានលើសខ្លាចគេមិនតាមយើងខ្លាចអញ្ចឹងហា៎!

កះហ្នឹងហើយ!!ខះបាទ!!កះញ៉ុមគិតថាពូបើសិនជានៅរៀនហា!!គឺខ្លាំងមែនទែនម៉ង បើសិនជាអត់សង្គ្រាមហ្នឹងម៉ងហាពូហា៎!!

ខះខ្ញុំ ខ្ញុំនិយាយថាមិនអួតទេអ្នកគ្រូខ្ញុំ ជំនាន់ខ្ញុំរៀនខ្ញុំលេខ១លេខ២រាល់ខែ។

កះហើយពូមិនព្រមបែកប៉ុល ពតហ្នឹងមិនព្រមរៀនទៀតអត់??

ខះអើរបែកប៉ុល ពតរៀនទៀតណាបើម្តាយចាស់បើម្តាយចាស់ដល់នេះមានអីរក មានតែយើងរៀនទៅគាត់ចេះគាត់ធ្វើអី?កាលយើងបែកមកយើងធ្វើស្រូវធ្វើអង្ករធ្វើស្រូវប្រាំងហ្នឹងយើងមកចិញ្ចឹមគាត់ដល់យើងរៀនទៀត ទៅរៀនទាល់តែអត់អីហូប វាពិបាក កាល កាលហ្នឹងចូលរៀនបានប៉ុន្មានខែដែរ ដល់ចូលទៅមើលទៅអត់កើត មើលទៅយើងប្រទាញប្រទង់ការងារអើរដូចថាធ្វើស្រែធ្វើស្រូវដូចថាវាអត់កើត អញ្ចឹងបានថាស្តាយដែរហ្នឹងហា៎!!

កះស្តាយមែនហ្នឹងហាពូហា៎!!បើនៅវិញហាពូមិនដឹងយ៉ាងណាទេពូហិ!!

ខះហើយបើបងញ៉ុមថាដែលធ្វើដុកទ័រដែលអាពតយកទៅសម្លាប់ហ្នឹងគាត់សួរញ៉ុមថាអូនឯងអើររៀនទៅអូនឯងចង់ជិះឡានហើជិះម៉ូតូ?សួរខ្ញុំអញ្ចឹង !!កះហ៊ឺ១!!ខះខ្ញុំថាអត់ហ៊ានថាទេបងអោយអីញ៉ុមយកហ្នឹង តែគាត់មានបានទាន់អោយអីអោយណាបើគាត់បានចេញមកធ្វើការមកសម័យមកគេយកគាត់មកសម្លាប់កោះគរនេះតើ!! កោះមុខផ្ទះនេះ។

កះហ្នឹងហើយញ៉ុមសំភាសន៍ពូចយប្រាប់ថាគេសំបូរណាស់គេសម្លាប់នៅអាមុខនេះអាកោះនេះហិ!!

ខះកោះគរហ្នឹងបើវាអាសម័យប៉ុល ពតគេហៅមន្ទីរ០៨។កះហ្ហ៎!!ខះកន្លែងសម្លាប់។

កះ០៧នៅទួលស្លែងពូហោ?

ខះបាទអានេះ០៨។

កះហ៊ុអ៊ឺចឹងបន្ទាប់ពីនោះមក?ខះបាទ!!កះនោះសាហាវណាស់?ខះបាទ!!កះអីយ៉ា!!ឥលូវពូនិយាយពីជំនាន់ប៉ុល ពតហ្នឹងមកម៉ងទៅភ្ជាប់ពីហ្នឹងហើយ??ម៉េចដែរពូ ថ្ងៃដំបូងពីជំនាន់ប៉ុលពតមកម៉េចដែរ?

ខ៖សម័យហ្នឹងអាហ្នឹងញ៉ុមនិយាយ និយាយដូចថាសម័យប៉ុល ពតហ្នឹងវាកាលហ្នឹងវាមិនទាន់ដឹងថាឃោរឃៅអីចឹងពេកទេ យើងអត់ទាន់ដឹងទេ ប៉ុន្តែកាលហ្នឹងគេខ្ញុំវានៅអាយុ១៣ ១៤ហ្នឹងគេយកខ្ញុំទៅចូលកងយុវជន យុវជនទី១ដំបូងចូលប្រឡាយ ជីកប្រឡាយអត់មានអោយយើងឈប់ទេ!!ហើយបើដល់នេះហើយចេះតែធ្វើអញ្ចឹងទៅហើយដល់ពេលជីកប្រឡាយគួរសមទេដល់ពេលអាផ្លូវជាតិថ្នល់វាល់ថ្ងៃអាផ្លូវទួលក្រសាំងហ្នឹងហាំ!!ហ្នឹងអ្នកគ្រូកុំច្រលំថាឡានជីកធ្វើហា!!កំលាំងពីមនុស្សវែកទេណាស់។

ក៖អាផ្លូវទួលហ្នឹងហី?

ខ៖ផ្លូវថ្នល់ទួលក្រសាំងរាល់ថ្ងៃអាផ្លូវពីតាខ្មៅមកយើងឈូងលៀបហ្នឹងវែកកំលាំងមនុស្សទេណាស់ញ៉ុមប្រាប់ហាំ!!

ក៖ធ្វើធ្វើផ្លូវហ្នឹងហេ?

ខ៖បាទធ្វើផ្លូវហ្នឹងហាំ!!ក៖ចំ!!ខ៖កំលាំងមនុស្សសុទ្ធសាធ។

ក៖ពូវែកហ្នឹងហេ?

ខ៖បាទវែកហ្នឹងតែខ្ញុំវែកចំអាកន្លែងជ្រៅហាំ!! អាកន្លែងមកពីទួលក្រសាំងអាកន្លែងជ្រៅជាងគេហ្នឹងហើយកន្លែងញ៉ុមវែក!!ក៖ហ៊ឺៗ!!ខ៖វាកំណត់អោយវែកពី គិតទៅម៉ាផ្លូវទួលក្រសាំងហ្នឹងមួយតាំងពីតាខ្មៅមកដល់យើងឈូងលៀបវាកំនត់៣ខែអោយហើយហាំ!!ក៖ចំ!!ខ៖វែកបង្កីយើងហ្នឹងហើយដីមិនមែនដីធូរដូចយើងឯណា ដីហ្នឹងដីសុទ្ធតែគ្រួសក្រហមហាំ ដល់តែដែកស្ពែងប៉ុនៗនេះបុកគាស់រំលើងមកវែចដែកស្ពែងគាស់ទៀតហា!!ក៖ចំ!!ខ៖បាទហើយគិតទៅកំលាំងយុវជនយុវនារីមួយស្រុកស្អាងមកលើកទាំងអស់។ក៖ហ៊ឺ!!ខ៖អ្នកណាម៉េចក៏ដោយវែកន្និនរួចយកទៅសម្លាប់យកទៅកសាង ថាយកទៅកសាងយកទៅប្រជុំមិនមែនយកទៅកសាងយកទៅប្រជុំទេណាស់តែកសាងហ្នឹងហើយមានតែចូលកោះគរយកទៅសម្លាប់កោះគរហើយអាហ្នឹងឃោរឃៅណាស់ អាហ្នឹងញ៉ុមនិយាយកាត់ អាហ្នឹងកុំនិយាយប្រលាយពេកញ៉ុមនិយាយតែវាត្រឹមហ្នឹងរបបវាហ្នឹងមកហើយដល់ពេលវែកដីហ្នឹងមកអីមកហើយគេអោយខ្ញុំទៅនៅត្រើយស្លាទៅឃុំត្រើយស្លាពួកយុវជនទៅវែកជីកប្រឡាយលើកភ្លឺហើយធ្វើទំនប់ហើយអាងអីហើយត្រើយស្លាទៅធ្វើនៅស្អាងភ្នំ ស្អាងភ្នំស្អាងស្រែក៏ប្រពន្ធ័ក៏ប្រឡាយភ្លឺកន្លែងញ៉ុមទៅធ្វើដេកនៅហ្នឹងដែរ។ក៖ហ៊ឺៗ!!ខ៖ហើយដល់ឡើងមកក្រោយឡើងគេអោយញ៉ុមមកព្យួរដីនៅ

ទូលក្រសាំងជាមួយកងយុវជនហ្នឹងហាំ!!គោគ្រាន់តែស៊ីស្លឹកស្វាយមួយយកទៅសម្លាប់ចោលស្លឹកស្វាយយើងហ្នឹង។

កះហ៊ីក៏ម្ល៉េះៗ!!

ខះបាទហើយថ្ងៃមួយ ថ្ងៃមួយអត់ចេញព្យួរ អត់ចេញព្យួរគោនៅកន្លែង គោនៅកន្លែងគេថាគោពួកខ្ញុំដែលគោនៅកន្លែងហ្នឹងអោយ អោយចេញទៅមុនទៅប្រលែងចេញអោយស៊ីមុនហើយអាក្រុមគេព្យួរចាំចេញទៅក្រោយគោពួកញ៉ុមមើលទៅមុនហ្នឹងមើលគ្នា៥នាក់ គ្នា៥នាក់គោជាង២០នឹម ហើយជាង២០នឹមហើយដល់នេះហើយគោពួកគេហ្នឹងម៉េចទេរួចទៅតាមគោ២ទៅដល់ទៅញ៉ុមអោយទៅហា២អី៥ ៦ទៅតាម ញ៉ុមថាអោយម្នាក់ទៅជួយមើលទៅគោច្រើនណាស់ញ៉ុមមើលអត់ឈ្នះទេ វាថាវាអត់ទៅ ដល់ហើយគោពួកខ្ញុំដែលទៅហ្នឹងអត់មើលដែរ ចុះគោចែកដាច់ចំនែកពីគ្នាអោយមើលយើងម៉េចទៅទទួលរបស់គេទៀត មិនអីចឹងដល់អីចឹងទៅមើលគោហ្នឹងវាធ្លាយមកស៊ីដំឡូងសហាករណ៍យើងឃុំសិត្បូរហ្នឹងហិ រកាខ្ពស់ហ្នឹង គេរំលាយរកាខ្ពស់ចោលគេដាក់សិត្បូរហ្នឹងហិ សិត្បូរហ្នឹង វាត្រឹមព្រែកថីឡើងមកសិត្បូរវិញហើយត្រឹមព្រែកថីចុះមកក្រោមដាក់ព្រែកគយ បាត់រំលាយឃុំរកាខ្ពស់ហ្នឹងមួយចោលដល់នេះមកស៊ីរបស់សហាករណ៍ សហាករណ៍ចាប់ ដល់ចាប់បានអាពួកនៅហ្នឹងវារាយការណ៍ញ៉ុម រាយការណ៍ថាញ៉ុមហ្នឹងអត់មើលគោអត់មើលអី ដល់នេះមេកងវាមកហៅខ្ញុំ ហៅខ្ញុំទៅដល់នេះថាហៅខ្ញុំទៅប្រជុំអប់រំណែនាំ ខ្ញុំនិយាយមុខម៉ងខ្ញុំអត់ខ្លាចថាហ៊ីខ្ញុំអត់ជឿថាយកខ្ញុំទៅប្រជុំអប់រំណែនាំទេយកខ្ញុំទៅកោះគរម៉ងញ៉ុមនិយាយអីចឹងញ៉ុមនិាយយអត់ខ្លាចថាយកញ៉ុមទៅកោះគរម៉ងដល់នេះគេឆ្លើយឡើងថាអត់ទេទៅអប់រំណែនាំកសាងទេ ញ៉ុមថាអត់ជឿទេញ៉ុមនៅតែទន្ទេញថាកោះគររហូតដើរវាអាមេកងគេហ្នឹងដឹកដើរនាំញ៉ុមយកទៅហ្នឹង ញ៉ុមនិយាយរហូតញ៉ុមថាញ៉ុមអត់ជឿទៅអប់រំណែនាំប្រជុំទេយកញ៉ុមទៅកោះគរ ញ៉ុមនៅតែទន្ទេញរហូត អត់អីទេមិត្តឯងកុំភ័យអត់មានយកទៅកោះគរទេ ហើយដល់នេះអាមេធំវាឈ្មោះអាសូត្រ កាលហ្នឹងនៅកាន់ស្រុកស្អាងឈ្មោះវាអាសូត្រ ដល់នាំខ្ញុំចេះចេញពីនេះចេញទៅពីអាកន្លែងទូលក្រសាំងចេះទៅពន្ទ័ទៅដល់ជិតតាខ្មៅទៅរកមេធំគេទៅរកអត់ឃើញគេពន្ទ័ចេះចេញទៅចេះទៅដល់តាមផ្លូវផ្ទះហ៊ុនសែនចេះតែរកមិនឃើញដល់នេះអាមេធំវាគេហៅ បើគិតទៅចុះពីថៅហ្វាយស្រុកមកគេស្រុកដែរណាស់ គេក្តាប់មួយស្រុកស្អាងដល់នេះទៅដល់ទៅសួរដល់អាកន្លែងគេហ្នឹងវាថាហ្នំមិត្តបងទៅចាក់ពស់នៅខ្សាកបាត់ហើយដល់នេះចាំមិត្តបងមកចាំទៅអញ្ជឹងគេថាអញ្ជឹង ដល់នេះគេថាហ៊ីមិត្តឯងចុះរែកដីនៅនេះសិនហើយ ញ៉ុមថាដល់ញ៉ុមនឹកឃើញមិត្តបងគេទៅខ្សាកហ្នឹងអញរួចខ្លួនថ្ងៃហ្នឹងស្អែកអញនៅតែកោះគរដដែល នៅតែទន្ទេញកោះគរហ្នឹង

ហើយដល់តែមកអោយខ្ញុំរែកដីរែកទប់ទំនប់អាហ្នឹងអាហ្នឹងឆ្នាំហ្នឹងទឹកជំនន់ធំហើយឆ្នាំ៧៦(១៩៧៦)៧៧(១៩៧៧)ទឹកលិចរែកដីក្នុងទឹកអ្នកគ្រូហាំ!!!អាបង្គីដែកប៉ុនៗហ្នឹងរែកដីក្នុងទឹកភក្លែកកភក្លួចៗៗរែកឡើងលើទំនប់រែកដីទាំងទឹកហើយភ្លៀងទៀត!!កះចំ!!ខះអាហ្នឹងជីវប្រវត្តិរបស់ញ៉ុមដែលសម័យបងពត អាហ្នឹងគាត់មួយទៀតចុះ។

កះញ៉ុមជេរឥឡូវហ្នឹងញ៉ុមក្រើតណាស់!!ខះបាទ!!កះអាក្រក់ម្ល៉េះពូ !!ខះបាទៗ!!កះហើយម៉េចទៀតទៅពូ?

ខះដល់នេះញ៉ុមថានៅតែដល់ហ្នឹងដេកយប់ថ្ងៃហ្នឹងស្អែកកោះគរហើយនៅតែទន្ទេញកោះគរតែដល់តែរួចទៅវាអោយរែកដីនៅហ្នឹងហ្នឹងវាអត់ឃើញអាមេកងមេកើយហ្នឹងហៅយើងទៀតអត់ វាឆឹងអត់!!

កះក៏រួចខ្លួនទៅ?

ខះបាទរួចខ្លួនដូចថាវាយកពីកន្លែងមើលគោយកយើងមកលន់ដំរែកដីនៅហ្នឹងហ្នំ!!!កះហ៊ឹ!»ខះហើយដល់នេះបានថាអើរនៅតែថាតែនៅទន្ទេញកោះគររហូតអញ្ចឹងដល់រួចទៅបានប្រហែលអាពេលគេថាអាសន្និបាត ១០ថ្ងៃ១ខែគេសន្និបាតម្តងគេថាមួយស្រុកស្អាងសន្និបាតនៅទៀតឥឡូវនេះគេហៅសិត្បូរគេហៅបន្ទាយស្រីបន្ទាយស្រីអាកន្លែងរោងចក្រអណ្តែងយើងឥឡូវនេះមួយសន្និបាតហ្នឹងគឺទាំងអស់យុវជនយុវនារីសហករណ៍ប្រជាជនម៉ែឪហ្នឹងទៅសន្និបាតហ្នឹងទាំងអស់ដល់នេះផែនការវាថ្ងៃហ្នឹងផែនការអើរសន្និបាតហ្នឹងផែនការវាធ្វើនំបញ្ចុកអោយយើងស៊ីដាក់ថ្នាំពុលសម្លាប់។កះហ៊ឹ!!ខះសម្លាប់ទាំងអស់ ហើយនឹង!!

កះនិយាយទៅញ៉ុមឮអាសម្លាប់ហ្នឹងពូគ្រប់ខេត្តទាំងអស់ពូហេ?

ខះបាទ ដាក់ថ្នាំពុលសម្លាប់ហើយវាដាក់មីន ដាក់បើសល់ពីសម្លាប់ពីទាញកន្ត្រាក់មីនអោយផ្ទុះងាប់ហ្នឹងទៀត។

កះចំសាហាវម្ល៉េះ!!

ខះហើយដល់ហើយនេះអាថ្ងៃគេសន្និបាតហ្នឹងខ្ញុំ ខ្ញុំអត់មកទេ!!ញ៉ុមនៅទួលក្រសាំងនេះតើ!!!

កះសន្និបាតនៅខេត្តណាវិញពូ?

ខ៖អើរសន្និបាត អាហ្នឹងគេសន្និបាតតាមស្រុកហា៎!!ក៖ហ៊ីៗ!!ខ៖អើរពីទួលក្រសាំងមកសន្និបាតយើងនៅយើងនៅសិត្បូរនេះ ឃុំសិត្បូនេះ !!ក៖ចា៎ៗ!!ខ៖ដល់នេះញ៉ុមថាហ៊ីអត់មកទេ ញ៉ុមអត់មកទេញ៉ុមនៅកន្លែងនេះញ៉ុមថា គេថាបើមិត្តឯងអត់មកនៅកន្លែងមើលគោផងអញ្ចឹង ដល់នេះស្រាប់ញ៉ុមអ៉តមកអើរដល់អត់មកនៅមើលគេដល់ជ្រួលច្របល់អើរថាគ្រាប់បែកនំបញ្ចុកអាគ្រាប់បែកក៏អត់បានទាញអានំបញ្ចុកក៏អត់បានស៊ីថាពួកយួនគេចូលមកគេវ៉ៃចូលមករំដោះ៧មករាហ្នឹង!!ក៖ហ៊ឺ!!ខ៖ហើយដល់នេះដល់មកចេះតែឃើញកប៉ាល់ហោះចេះតែប្រទ្រុយៗអញ្ចឹងមកដល់នេះរួចទៅខ្ញុំឃើញគេរត់ជ្រួលច្របល់ទាំងអស់គ្នាអាមេកងគេថាមិត្តយើងទៅលិចភ្នំលិចទាំងអស់ ញ៉ុមថាអញលិចម៉ែហ្អែងអីអញទៅកើតហើយថាអញ្ចឹង ខ្ញុំបានគោមួយនឹមញ៉ុមដឹកគោគេទៅអញ្ចេះគ្រប់គ្នាញ៉ុមទៅបញ្រ្ចាស់ចេះមករត់រកម្ដាយញ៉ុម ម្ដាយញ៉ុមគាត់នៅចាំមើលកូនគាត់អត់ហ៊ានដូចថាផ្ទះសម័យអាពតផ្ទះម្ដងនៅនេះម្ដងនៅណោះអ៊ីចឹង។ក៖ចា៎!!ខ៖គាត់នៅចាំផ្ទះហ្នឹងគាត់មករកទំរាំឃើញហើយបាត់ទៅក្រោមទាំងអស់គ្នាដល់នេះវាគារចុះទៅដល់ទៅដល់វាគារទៅដល់ព្រៃកតូចវាគារចុះទៅថាចុះទៅលិចទៅទៀតដល់នេះមិនទៅតាមវាណាបើសុទ្ធតែកាំភ្លើងច្រូងច្រាំងដល់នេះទៅដល់ក្នុងទៅដល់ផុតភ្នំស្អាងអ៊ីចឹងមានអាផ្លូវមួយពន្ធ័មកវិញពន្ធ័មកទន្លេវិញអាវាទៅណោះទៅញ៉ុមចេញមកវិញពន្ធ័ចេញមកវិញតាមទន្លេទៅបានមកនៅដល់ហ្នឹងដល់សព្វថ្ងៃហ្នឹង!!

ក៖ចា៎ អ៊ីចឹងគឺប្រវត្តិប៉ុល ពតគឺពូអ៊ីចឹងម៉ងពូហោ?

ខ៖បាទ!!

ក៖ចា៎អ៊ីចឹងឥឡូវម៉េចពូគ្រាន់តែសង្ខេបៗអត់ទាន់បាននិយាយពេលពូនេះអើរការហូប ការហូបចុកពូម៉េចដែរ ធ្វើការខ្លាំងមែនទែនម៉ងពូហោ៎??

ខ៖ហូបចុកហ៊ីបើនិយាយធ្វើការដឹងហើយ បើថាហូបចុកបបរវាល់វែក។

ក៖ម៉េចវិញទៅពូ?

ខ៖អាវែកយើងអាវែកសំលរយើងវែកសរប៉ុនហ្នឹងហ្នឹង!!ក៖ចា៎!!ខ៖វាល់៣វែកអ៊ីចឹងទៅ បើនេះគេហៅអាកាទឹកហ្នឹង អាការទឹកហ្នឹងបើវាល់ចំនួនអង្ករយើងវិញអាកាកហ្នឹងថា២កំប៉ុងអង្ករយើងទៅវាល់ វាល់ដាក់អោយយើងវាវាល់ទឹកហា៎!!វាវាល់ក្នុងមួយការក្នុងមួយនាក់វាវាល់មួយការហ្នឹងបើចំរិតយកជាកាកយកបបរវិញប្រហែលជាមួយស្លាបព្រាបាយយើងហ្នឹង។

កះចំហើយអោយធ្វើការខ្លាំង?ខះបាទ!!កះហើយអោយឡើងរែកដីចេញពីក្នុងទឹក។

ខះបាទ នៅក្នុងមួយពេលមួយការហ្នឹងហើយបបរកាកអង្ករហ្នឹងប្រហែលជាមួយស្លាបព្រាទេ។

កះហើយអ៊ីចឹងធ្វើម៉េចបានមានកំលាំងទៅពូទៅរកអីគេថែម?

ខះយើងមានអីគេថែម !! និយាយពីក្បាលជង្គង់ធំជាងខ្លួនទៀតហ្មំ!!ធំជាងក្បាលទៀតហ្មំ!!ឥឡូវត្រមែងៗហើយក្មេងអាយុប៉ុនកូនញ៉ុមអាពៅនេះអីវ៉ាន់អើរអោយទូលអាចមន៍គោអីអ៊ីចឹងទៅ!! ទៅជីកក្លឺលើកក្លឺលើកអីអង្គុយអ៊ីចឹងមើលពីចំងាយមើលទៅដូចស្វាឬក៏ចាស់រយរាជអ៊ីចឹង ក្មេងៗអាយុ៣ ៤ ៥ឆ្នាំហ្នឹង!!

កះវាអត់អានិតសោះម៉ងពូហេ??

ខះបាទបាទ!!ហេបានថា ហើយរឿងហូបចុកពីអត់ឃ្លានហ្នឹងហួសពីនិយាយទៅហើយពួកស្មានមិនដល់ទេ។កះចាំ!!ខះហើយជួនកាលអាពេលព្រឹកហ្នឹងរបបកាលនៅនេះរបបពេលព្រឹកមុនដំបូងផ្លែ ចេកយើងចេកទុំចេកយើងចេកដាក់ស្ងោរហ្នឹងក្នុងមួយនាក់បាន បាន២របបមួយពេលហ្នឹងបានចេកស្ងោរ២ ដល់ក្រោយឡើងគ្នាមួយវង់គ្នា១០នាក់ដាក់ចែកដែរ១០ដែរ ម្នាក់របបចែក១អើរវាចង់សម្លាប់យើងមែនទែនហើយបានវាដាក់អញ្ចឹង!!កះហ៊ឺ!! ខះហើយដល់ក្រោយឡើងលែងដាក់ចេក៥មកគ្នាយើង១០នាក់ ដល់អញ្ចឹងពួកហ្នឹងងើបដើរចេញអស់មានអ្នកណាហូប ចេះអញ្ចឹងដល់អ៊ីចឹងអាហូបអាណាអត់ យើងគិតមើលចេក៥គ្នា១០នាក់។

កះដំបូងវាកាត់បន្ថយបន្តិចម្តងៗពូហាំ!!ខះបាទ!កះទាញមនុស្សអោយបាក់កំលាំងតិចម្តងៗហ្មំ!!

ខះហើយស្រូវអង្ករ ជង្រុក ណែនជង្រុកទាំងអស់នៅទួលក្រសាំង ឃ្លាំងប៉ុនៗណាណី!!

កះពូដឹងថាវាទុកក្នុងឃ្លាំងហ្នឹងដើម្បីអីគេអត់?

ខះវាយកទៅចិន ហើយដល់នេះបានដល់នេះដល់ថាជួនកាលដំឡូងផ្វាមួយពេលក៏មានដែរអ្នកគ្រូដំឡូវផ្វាមានដាក់ស្អីប៉ុនមេជើងប្រវែងហ្នឹងហើយបើនេះយើងពោតទុំពោតក្រហមស្ងោរអោយយើងមួយពេលមួយ ហើយបើសំលរវិញត្រកួនយើងអាត្រកួនយើងគេហៅអាសំលរទឹកប៊ិចហ្នឹង ទឹកប៊ិចជាគ្នាម៉េចអ៊ីចឹងដល់ហើយមិនបានត្រកួនខ្ចីដូចយើងទេអ្នកគ្រូហាំអាត្រកួន

ចាស់ ត្រកួនចាស់ជាងត្រកួនអោយជ្រូកស៊ីទៀតហ្នំ!!កះចំ!!ខះច្រូតទៅ ច្រូតយកមកអោយស្ងួរអោយយើងស៊ីម៉ង!!

កះចឹបានអាល្អៗវាមិនព្រមចែកគ្នាខ្លះចឹ?

ខះមិនដឹងម៉េចវាធ្វើអោយយើងស៊ីអញ្ចឹង ហើយបើមេវាសុទ្ធស៊ីសាច់ជ្រូកសាច់គោណោះ!!កះហ៊ឺ!!ខះហើយយើងស៊ីវាធ្វើអញ្ចឹងអោយយើងស៊ី !!

កះហ៊ឺ!!លោកពូមានដែលធ្លាប់ឃើញអ្នកណាយកមនុស្សទៅសម្លាប់ចោលនៅមុខអីអត់?ដែលឃើញលបមើលឃើញអីអត់?

ខះវាអត់ដែលឃើញសម្លាប់ម៉ងតែគ្រាន់តែថាថ្ងៃមួយញ៉ុមនៅកង អាកងយុវជនហ្នឹង គេថាមិត្តយើងកុំចេញក្រៅហាំ!កុំចេញពីរោងគេដេកវែងៗអាខ្សែគេវែងៗមិត្តឯងកុំចេញទៅក្រៅហា អើរមិត្តបងយើងដើរធ្វើការថាអញ្ចឹងហាំ !!ខ្ញុំនេះថាគេអត់អោយចេញដើរទៅក្រៅដល់នេះដើរចេញមកដល់ដើរចេញមក អត់ចេញអោយផុតពីរោងដេកទេ ចេញមកនៅឈរមាត់ទ្វារហ្នឹងមកឃើញបណ្ដើរម៉ងបណ្ដើរចងសេកអញ្ចឹងហ៎ ចងសេកដៃទៅក្រោយអ៊ីចឹងហ៎!!។

កះមនុស្សប៉ុន្មាននាក់ពូ?

ខះមួយខ្សែហ្នឹងមានតែ២០ ទៅ៣០នាក់!!កះចំ!!ខះចងសេកហើយខ្សែគោចងប្រហូតពីមុខដល់ខាងក្រោយ!!កះហ៊ឺ!!ខះហើយដល់នេះអាដល់អញ្ចឹងហើយអាមុខអាខ្សែមុខហ្នឹងវាចងជាប់កន្ទុយកង់យើងហ្នឹងយើងវាជិះ!!កះហ៊ឺៗ!!ខះអាមេកងហ្នឹងវាជិះអោយអាអ្នកទោសជាប់ដៃហ្នឹងអោយរត់តាមវា។កះចំ!!ខះហើយដល់នេះអាអ្នកក្រោយ អាអ្នកក្រោយវាជិះកង់ដៃរវាមានរំពាត់ខ្សែតីមួយវ៉ៃអោយលឿនៗៗលឿនៗ!!

កះខ្មែរឯងសោះហ្នឹងញ៉ុមឆ្ងល់ណាស់ពូ!!

ខះដល់តែហើយមើលតែដួលត្រហាត់ត្រហឹងអ៊ីចឹង ងើបៗៗវ៉ៃអោយងើបទៀត ហើយដៃគ្នាអាជាប់សេកអញ្ចឹងគ្នាម៉េចងើបរួចអ្នកគ្រូឯងគិតមើល!!ហើយដល់ហើយខ្ញុំឃើញតែម្ដងហ្នឹងខ្ញុំឃើញអស្ចារ្យដល់ក្រោយឡើងអោយតែគេថាមានមិត្តបងយើងដើរធ្វើការអោយតែមកលួចមើលគឺឃើញតែចងសេកអញ្ចឹងដឹកទាំងខ្សែៗ។

កះរហូតម៉ងពូហេ?ខះបាទៗ!!កះអើយពូអើយពូ!!

ខះហើយអញ្ចឹងបានថាអើរខុសអីបន្តិចបន្តួចថាអើរគេយកទៅប្រជុំអប់រំកសាងណែនាំគឺអត់កសាងណែនាំទេ គឺយកមកសម្លាប់នេះអាកន្លែងឈៀងត្រង់នេះ ត្រង់កន្លែងនេះកំពង់ចំលងយកទៅសម្លាប់នៅកោះគរនេះ នេះមិនមុខវត្តឈូងលៀបមួយទៀត!!

កះដាក់ទូកយកទៅសម្លាប់ម៉ង?

ខះបាទដាក់ទូកយកទៅ យកទៅបង្អត់អាហារយើងអ៊ីចឹង ហើយដល់ឆ្នាំបែកដំបូងញ៉ុមទៅដល់ឃើញដើមស្វាយមួយដើមដើមធំណាស់ណោះប៉ុនណោះសុទ្ធតែដែកគោលនៅជាប់ពេញដើមស្វាយហ្នឹងតែថាវាយកយើងទៅដល់ឆ្កាងនៅនឹងដើមស្វាយអ៊ីចឹងបោះជាប់បាតដៃបាតជើងអញ្ចឹងវ៉ៃស្លូរចម្លើយទាំងអស់។កះអូយ!!!ខះខ្ញុំឆ្នាំបែកហ្នឹងខ្ញុំទៅឃើញដើមស្វាយហ្នឹងតើ!!!ទៅឃើញទៅឃើញដែកគោលនៅពេញទាំងអស់។

កះហើយដើមស្វាយហ្នឹងនៅដល់ឥឡូវទេ?

ខះអត់ទេដើមស្វាយហ្នឹងដល់តែវ៉ៃនេះអញ្ចឹង ដើមស្វាយទៅជាងាប់ទៅ ដើមស្វាយហ្នឹង!!កះហ៊ឺ!!ខះបែកទៅដំបូងច្រូតស្មៅគោទៅច្រូតលើផ្នូរខ្មោចមានដឹងណាអាអន្លង់ខ្មោចហើយអាស្មៅឡើងដើមចង់ប៉ុនៗមេឡើងល្អ។

កះវាល្អពេកហោ?

ខះហើយដល់នេះស្រាប់ដល់នេះវាថាស្លូរហ្អែងច្រូតស្មៅណាល្អៗ ហ៊ឺច្រូតកន្លែងណោះ ហ្វាំហ្អែងច្រូតកន្លែងខ្មោចហ្នឹង ដឹងខ្មោចមិនខ្មោចបើដូចថាផ្នូរខ្មោចគេលប់ដីជិតអស់ហើយយើងអត់ដឹងហាំ!!កះហ៊ឺៗ!!ខះបាទ!!

កះអូយ!!សាហាវណាស់ពូណោះ?ខះបាទ!!កះអញ្ចឹងកន្លែងកោះខាងណោះហ្នឹងគឺសំរាប់ទុកខ្លៃវ៉ៃមនុស្សងាប់ម៉ងពូហោ?ខះបាទ!!កះហើយមមានដែលឮសំលេងអីឆ្ងាយមកដល់នេះអីអត់ស្រែកអីអ៊ីចឹងហាំ??

ខះឆ្ងាយណាបើយើងពួកយុវជនពួកហ្នឹងម៉ែឪអ៊ីចឹងមិននៅនឹងភូមិផងក៏អត់បាននៅផងទៅនៅបឹងគេហៅថាអាកន្លែងកសិដ្ឋានរោងនៅធ្វើស្រែធ្វើស្រូវណោះ!!ផ្ទះនេះជំនាន់អាពតដូចព្រៃខ្មោចអ៊ីចឹងហ្នឹង!!អត់មានមនុស្សនៅផងព្រៃហើយផ្លូវ ផ្លូវថ្មល់យើងមានផ្លូវណាសុទ្ធតែវល្លិរោមជិតទាំងអស់អ៊ីចឹងមានមនុស្សណានៅ!!ហើយអ៊ីចឹង!!

ក៖អត់មានអ្នកណារត់គេចទេអ៊ីចឹង?

ខ៖រត់គេចណាបើសិនជាគេសុទ្ធតែកាំភ្លើងហើយចងសេកទាំង២ហើយយើងតដៃគេណាបាន យើងស៊ីមិនឆ្អែតផងធ្វើម៉េចហ្នំ!!

ក៖មានអ្នកណាគេរើបំរាស់កើតទេ??

ខ៖រើណាកើតបើរើណាកើតមានស្អីរើណាកើតអាមួយនោះឈ្មោះផុន ផុនហ្នឹងសម័យលន់ នល់គេក្បាច់តែក្វាន់ដូអីនោះដល់ទៅដល់កោះគរហ្នឹងនេះម៉ងអត់ទាន់ចងអត់ទាន់អីទេដល់ទៅដល់ដឹងវាវ៉ៃម៉េចទេដល់តែអាហ្នឹងត ចងសេកជាប់ហើយដល់វ៉ៃ វ៉ៃហើយយកកាំភ្លើងមកផ្ទុងចេះវាទាត់ ទាត់ទៅទាល់តែបាក់កាំភ្លើងជា២។

ក៖ហ៊ីហើយម៉េចទៅអ៊ីចឹង?

ខ៖ហើយដល់បាក់កាំភ្លើងជា២វាខឹង ហ៊ីហ្អែងខ្លាំងហេ ខ្លាំងយកទៅបាញ់ចោលនៅក្នុងរណ្ដៅម៉ង។

ក៖បាញ់ពូអ្នកវ៉ៃហ្នឹងហេ?

ខ៖បាទ ចុះវាជាប់សេកហើយវាតអីអត់កើតជើង ជើងវ៉ៃទាត់បាក់កាំភ្លើងដល់វាខឹងវាវាបាញ់សំលាប់ចោល។

ក៖ចំ ពូញ៉ុមអានិតញ៉ុមឃើញទិដ្ឋភាពមើលយើងប៉ះអីឈឺតិចតួចយើងឈឺប៉ុនហ្នឹងហើយចុះទំរាំតែអើយធ្វើទារុណកម្មទំរាំដល់ស្លាប់នេះហ៎!!!ខ៖បាទ!!ក៖ពូជំនាន់ប៉ុល ពតហ៎ាសំលាប់ដោយសាហាវខ្លាំងបំផុតហា ញ៉ុមគិតថាមានតែជនជាតិខ្មែរយើងទេគឺការសម្លាប់គឺថាសាហាវខ្លាំងជាងគេបំផុតនៅលើសង្គ្រាមទាំងអស់នៅលើពិភពលោក។

ក៖ហើយខ្មែរជនជាតិខ្មែរយើងបើគិតទៅមិនមែនជនជាតិបរទេសមកសំលាប់ទេ គឺខ្មែរខ្លួនឯងសំលាប់ខ្មែរខ្លួនឯងតែម្ដងៗ!!

ក៖ហ្នឹងហើយ!!តាមពិតពូអត្តចរិករបស់ខ្មែរពិតប្រាកដមិនមែនអ៊ីចឹងទេណាស់!!ញ៉ុមអត់ដឹងថាការពង្វក់ខួរក្បាលរបស់គេហ្នឹងយ៉ាងម៉េចទេបានដល់ថ្នាក់ហ្នឹងពូណោះ??

ខ៖យើងអត់ដឹង អត់ដឹងគេមានគំនិតម៉េច!!!

កៈចាំ!!ពូដឹងថាមូលហេតុអីបានកើតសង្គ្រាមប៉ុល ពតហ្នឹងទេ?ពូមានដែលដឹងប្រវត្តិអីមួយហ្នឹងទេ?

ខៈយើងវាមិន យើងដំបូងយើងមិនដឹងថាវាមានកើតសង្គ្រាមប៉ុល ពតអីយើងគ្រាន់តែដឹតងថាឆ្នាំមុន៧០(១៩៧០)គេធ្វើរដ្ឋប្រហារទំលាក់សម្ដេច ទំលាក់សម្ដេច លន់ នល់ ទំលាក់សម្ដេចហើយដល់តែរួចហើយសម្ដេចដល់ទំលាក់លោកមិនចូលព្រៃ។កៈចាំ!!ខៈតស៊ូ ដល់តែពេលអើរជំនាន់អើរសម្ដេចចូលព្រៃគេមិនមែនហៅប៉ុល ពតណា!!គេហៅខ្មែររំដោះ។កៈចាំ!!ខៈដល់ខ្មែររំដោះដល់ហើយគេវ៉ៃរំដោះដល់តែខ្មែររំដោះហ្នឹងវ៉ៃលន់ នល់បែកហ្នឹងគេថាវ៉ៃដោយសារវ៉ៃអោយសម្ដេចឪជួយសម្ដេចឪទព័សម្ដេចឪ ដល់នេះបើសិនណាធ្វើសង្គ្រាមយើងគិតមើលស្មានតែឈ្នះលន់ នល់ហេ??លន់ នល់ គ្រាប់ពីអាមេរិកមកគ្រាប់ពីជំនួយមកយន្តហោះទំលាក់ក្នុងយន្តហោះមួយថ្ងៃហ្នឹង បើគេថាពួកអាកន្ទុំរុយមកមួយវ៉ូងវាអញ្ជឹងមកម្ដង១៥ ២០ឈរចំកាំងបាញ់ហើយ ហើយបើស្លាប!!

កៈពីលើមកម៉ងហេពូទំលាក់ភិបៗៗម៉ង?

ខៈវានៅចំកាំងវានៅនឹងស្ដូកពីលើហើយវាបាញ់ទំលាក់មកហើយទំលាក់គ្រាប់មកហើយ១៥ ២០យន្តអីវ៉ាន់ បើគេហៅអាស្លាបកាត់គេនោះវិញម្ដង៣ម្ដង៥ទៅមកទៅមកទំលាក់គ្រាប់អាធំៗហ្នឹងហើយបើសិនណាបើឧទាហរណ៍បើសិនណាកុំចាញ់នយោបាយរឿងអើររឿងសម្ដេចហ្នឹងស្មានលន់ នល់ ស្មានតែចាញ់ហីគ្រាប់គេគ្រប់គ្រាន់យើងវិភាគមើល!!ហើយបើខាងខ្មែររំដោះនេះអើរមានតែគ្រាប់តែមួយចង្កេះមួយចង្កេះហ្នឹងមានអីយើងវិភាគមើលហើយទៅឈ្នះយើងប្រៀបធៀបមើលហ្វ៎ អីចឹងបានថាយើងបានថាទៅចាញ់នយោបាយ ដល់ចាញ់នយោបាយគេលន់ នល់ ចាញ់នយោបាយខាងណោះវាទៅ វាទៅឈ្នះបានខាងណោះដល់ហើយគេស្មានតែសម្ដេចនៅគ្រប់គ្រងប្រទេស មានដឹងថាមានខ្មែរក្រហមប៉ុល ពតនឹងចូលមកមួយត្រលប់ចូលមកទៀតណា ហ្នឹងអញ្ជឹង!!កៈអូយ!!ខៈវាដល់នេះ មុនដំបូងខ្មែររំដោះទេ ដល់អស់ខ្មែររំដោះវាចូលប៉ុល ពត អៀង សារីនេះ!!ហើយខៀវ សំផនដែរហើយដល់ខៀវ សំផន វាវាអើរគាត់ដូចបាត់ឈ្មោះទៅលីសូរដូចខ្លាំងជាងគេដូចតែប៉ុល ពតហើយអៀង សារីហ្នឹង!!!កៈហ៊ីៗ!!ខៈហើយដល់នេះក៏បាត់ប៉ុល ពត អៀង សារីហ្នឹង ចេញតាម៉ុកតាម៉ុកថាចេញពីភូមិភាគនារតី អាតាម៉ុកហ្នឹងចេញមកកាលហ្នឹងប្រជុំនៅទួលក្រសាំងនេះ!!តាម៉ុកហ្នឹងញ៉ុមឃើញកាលហ្នឹងតាហ្នឹងខ្លាំងមែនអាហ្នឹង!!

កៈម៉េចទៅពូ?

ខះខ្លាំងណាស់ កាចណាស់ អាតាហ្នឹងកាលហ្នឹងចេញមកចុះមកអត់មានប្រជុំអីយើងទេ មកឃើញយើងកំពុងសន្និបាតប្រជុំទៅវាថាអើរថាមិត្តយើងគ្រាន់តែញុំមសូមតែផ្តាំផ្ញើរទេណាស់បើអង្គុយអង្គុយអោយចំកៅអីសមូហភាពណាស់កុំអង្គុយអោយផ្អៀងកុំអង្គុយអោយខុសណាស់លូកដៃបាក់ដៃលូកជើងបាក់ជើងកង់ប្រវត្តិសាស្រ្តវិលទៅមុខហើយ។កះចំ!!ខះហ្នឹងអាហ្នឹងតាម៉ុកហ្នឹងថាអញ្ចឹងម៉ង!!

កះតាម៉ុកហ្នឹងខ្មែរយើងតើពូណោះ?

ខះខ្មែរហ្នឹង។

កះតែតាម៉ុកគិតថាតាម៉ុកគំនិតអីវ៉ាន់ដូចប៉ុល ពតទេពូ?ញុំមអត់ដឹងពីគាត់ផង!!

ខះប៉ុល ពតយើងគ្រាន់តែលឺសូរតែឈ្មោះតែបើថាអ្នកអនុវត្តន៍អ្នកបញ្ជាអោយធ្វើគឺតាម៉ុកនេះ!! ណោះអាហ្នឹងបើតាមញ៉ូមដឹងហាំ!!វាអញ្ចឹង!!

កះអ៊ីចឹងមានតាម៉ុកមកខាងក្រោយនេះទៀត??

ខះអាហ្នឹងដឹងយើងយ៉ាងម៉េចដល់អញ្ចឹងដល់យើងរាល់ថ្ងៃដល់ប៉ុល ពត អៀងសារីមានសូរលឺសូរអីណា!!ល្បីតែតាម៉ុកវិញហើយឃើញទេ!!កះហ៊ុៗ!!ខះវាអញ្ចឹងហិ!!

ខះផ្ទូរប៉ុល ពតពូញ៉ូមទៅពេលមុនហាំ!!នៅជិតទល់ដែនថៃនៅឧត្តរមានជ័យហ្នំ!!ខះបាទ!!កះហើយទៅទៅអាកន្លែងស្អីគេ តាតាម៉ុកហ្នឹងដែរ!!ខះបាទ!!កះគេកន្លែងគេធ្វើទ័ពអីហ្នំពូ!!

ខះបាទ!!តាម៉ុកគេថានៅលង្វែកហីផ្ទះ??

កះហ្នឹងហើយអន្លង់វែងឧត្តរមានជ័យហ្នឹងពូ!!ខះបាទ!!កះទៅឃើញអញ្ចឹងឃើញនេះផ្ទូរអាមនុស្សអើរដែលបង្កអោយមានសង្គ្រាម តាមពិតពូញ៉ុមគឹតថាសង្គ្រាមនៅប្រទេសខ្មែរយើងហាំមានអាថ៌កំបាំងច្រើនដែលពួកជនជាតិយើងអត់ដឹងសោះ មានដែលអ្នកធំៗអីវ៉ាន់លើទេបានគាត់ដឹង!!

ខះយើងគិតទៅថាអញ្ចេកខ្មែរយើងវាមានអាថ៌កំបាំងច្រើនហើយបើសង្គ្រាមខ្លាំងដល់យើងសង្គ្រាមខ្លាំងទៅវាយើងទៅយើងបានតែឈ្លោះគ្នាកាប់ចាក់គ្នា តែដល់ ដល់រឿងបាត់ទឹកដីអាយើងយើងអ្នកឈ្លោះគ្នាអាគេអ្នកត្របាក់យើងវារិភាគអញ្ចេក។

កះគិតមើលមើលស្រូវអត់អោយប្រជាជនឯងហូបទេសម្លាប់រង្គៀល ដឹកទៅប្រទេសគេ!!ខះបាទ!!កះសាហាវណាស់ពូហ្អើយ!!ពូចុះពេលជំនាន់លន់ នល់ ពូមានឃើញគ្រាប់ដែលគេទំលាក់មកផឹងៗអ៊ីចឹងម៉ងហេ?

ខះឃើញញ៉ុមរត់ចូលត្រង់សេ បើសិនណាវាទំលាក់ចំក៏ងាប់ដែរ គ្រាប់វាទំលាក់ចូលក្នុងដីជំរៅណាណី!!៥ ៦ម៉ែត្រអញ្ជឹងជំរៅដែលនៅហ៎ា!!

កះទោះយើងនៅអោយតែធ្លាក់ចូលក្នុងត្រង់សេក៏ត្រូវតែស្លាប់ដែរពូមែនទេ??

ខះមិន!!បាទ!!

កះតែនិយាយទៅ ចូលទៅក្នុងហ្នឹងកុំតែអោយវាឃើញថាមនុស្សទៅពូណោះ??គេថា!

ខះវា !!កះម៉េចដែរពូ?ខះវាបើសិនណាវាទំលាក់ហើយបើគោលដៅវាទំលាក់គ្រាប់បែកកាលពេលជំនាន់លន់ នល់ បើវាទំលាក់តាមក្នុងភូមិវិញប្រជាជនគ្មានសល់ទេ!!កះហ៊ឺៗ!!ខះតែដូចថាវាមកបាញ់ទំលាក់ក្នុងព្រៃក្នុងបឹងអីទៅណាស់ វាចេះតែទំលាក់គ្រាប់បែកអ៊ីចឹងទៅ។

កះតាមពិតសុទ្ធតែដឹងអីដែរហ្នឹងមែនពូមែនទេ?ខះបាទ!!កះអត់ចង់អោយប្រជាជនស្លាប់ទេប៉ុន្តែញ៉ុមឮគេថាដើម្បីសម្លាប់ទ័ពប៉ុល ពតហ្នឹងមែនទេពូ?

ខះហើយយើងថាសម្លាប់ទ័ពប៉ុល ពតទ័ពវាថាអាទ័ពវាទំលាក់ក្នុងបឹង ថាទ័ពនៅក្នុងព្រៃ ដល់ទំលាក់ក្នុងព្រៃដល់អាទ័ពវានៅក្នុងព្រៃវាក្នុងជាមួយប្រជាជនហ៎!!ហើយបើសិនជាណាទំលាក់ក្នុងភូមិវាមិនងាប់ប្រជាជន។

កះអញ្ជឹងក៏អត់ទៅ?

ខះបាទហើយឧទាហរណ៍ថាបើសិនណាយើងអ្នកដឹកនាំរាល់ថ្ងៃក៏ដោយយើងថាអញ្ចេកបើយើងដឹកនាំបើអត់ប្រជាជនយើងដឹកនាំកើតហេ!!យើងវិភាគថាអញ្ចេក។

កះដឹងអោយអ្នកណាគេគោរពអ្នកណាគេ?

ខះបាទ!!!!បើអញ្ចេក យើងធ្វើថ្នាក់ដឹកនាំទាល់តែមានប្រជាជន តែបើអត់ប្រជាជនដឹកនាំម៉េចយើងគិតមើល!!អាហ្នឹងអញ្ជឹង!!

ក៖ហុី១!!ចាំ នយោបាយហាល្បិចគេចកលច្រើនណាស់ពូមែនទេ??ខ៖បាទ!!ក៖វារឿងអីដែលកំបាំងច្រើនណាស់!!អ៊ីចឹងពូបងលោកពូដែលបើកឡានពេទ្យហ្នឹងគាត់ស្លាប់នៅក្នុងជំនាន់ប៉ុលពតហ្នឹងហេ?

ខ៖អត់ទេ!!គាត់ស្លាប់មក មក គាត់ជិះកាលគាត់មកលេងញ៉ុមនេះកាលគាត់ជិះកង់គាត់នៅផ្ទះគាត់នៅនេះ ជិះកង់មកនេះទៅផ្ទះ ទៅផ្ទះវិញគាត់ឆ្លងទៅម៉ូតូគេគារបោកគាត់ទៅគ្រោះថ្នាក់តែអត់ទាន់ស្លាប់ដល់បានប៉ុន្មាន បានប៉ុន្មាន ១ឆ្នាំ២ឆ្នាំទៀតបានគាត់ស្លាប់។

ក៖ចុះបងប្អូនលោកពូទាំង៨នាក់ហ្នឹងអ្នកណាគេខ្លះស្លាប់នៅក្នុងជំនាន់ប៉ុល ពត?

ខ៖ស្លាប់នៅក្នុងជំនាន់ប៉ុល ពត  ស្លាប់នៅក្នុងជំនាន់ប៉ុល ពតស្លាប់តែមួយទេជំនាន់ប៉ុល ពតតែបងញ៉ុមធ្វើពេទ្យហ្នឹងបងទី២ហ្នឹងមួយទេ!!

ក៖ចាំ!!គេយកទៅសម្លាប់ចោលឬក៏គាត់ស្លាប់ដោយខ្លួនឯងពូ?

ខ៖គេយកទៅសម្លាប់ទៅនេះកោះគរហ្នឹង!!

ក៖ចាំ ពូមានដឹងថាគេយកគាត់ទៅសម្លាប់រឺក៏គាត់ដឹងខ្លួនមុនអីអត់ពូដឹងទេ?

ខ៖ហុឺ!!គាត់អញ្ចេកម៉េចបានថាគាត់ពិបាកគាត់ធ្វើពេទ្យហើយគាត់បែកពីយើងនល់ នល់មក៧៥(១៩៧៥)មកគាត់មានថ្នាំពេទ្យគាត់មានសឺរ៉ាំងចាក់ថ្នាំអីទាំងអស់មកណាស់!!

ក៖គេដឹង។

ខ៖គេថាថាគាត់ថាហ្អែងកុំនេះអ៊ីចឹងថា ប្រយត្ន័គេដឹងរើយ!!ហើយដល់ហ្នឹងកាលគាត់បែក៧៥(១៩៧៥)មកភ្លាមគាត់យកមកនៅមានថ្នាំពេទ្យមានអីហើយឪពុកញ៉ុមក៏អត់ទាន់ស្លាប់ដែរកាល៧៥(១៩៧៥)ហ្នឹងហា!!ក៖ហុឺ!!!ខ៖ហើយបងញ៉ុមហ្នឹងគាត់មានថ្នាំចាក់គាត់ថ្នាំព្យាបាទគាត់ដល់អស់ថ្នាំថ្ងៃហ្នឹងអត់ថ្នាំចាក់អោយគាត់គាត់ក៏ស្លាប់ថ្ងៃហ្នឹងដែរ!!ក៖ចំ!!ខ៖កាលហ្នឹងគាត់រស់ដោយសារថ្នាំដល់នេះ រួចទៅអាអ្នកដែលនៅក្នុងស្រុកដែលស្គាល់អោយតែឃើញគាត់សុទ្ធតែលោកគ្រូពេទ្យ លោកគ្រូពេទ្យគ្រប់គ្នា អាហ្នឹងដូចបង្ហើបកកាយអោយគេដឹងអញ្ចឹង!!

ក៖អូ្វយហ្នឹងហើយ!!

ខ៖ហើយមានអាអ្នកស្គាល់ក្នុងស្រុកហ្នឹងមានអ្នករាយការណ៍ថាអានេះធ្វើនេះអានេះធ្វើនោះអញ្ចឹង ដល់នេះរាយការណ៍ហើយដល់យើងយើងទៅសំលាប់ហើយដល់ចុងក្រោយសួរនៅអាណាទៀត ថាអស់ហើយ ដល់អស់ហើយអាអ្នករាយការណ៍ហ្នឹងក៏គេយកទៅសម្លាប់ដែរហ្នឹង!!ក៖ហ៊ឺ!!ខ៖អាហ្នឹងអោយវាដឹងថាអាហ្នឹងអស់នៅអស់ហើយខ្លួនឯងដែរហ្នឹង!!

ក៖ហ្នឹងហើយ ចំនេះជិះករឯងដែរហ្នឹងពូហោ??

ខ៖បាទ!!បាទ!!

ក៖តែពេលខ្លះ ដឹងថាគេយកទៅសម្លាប់ចោលដែរហោ??ខ៖បាទ!!ក៖ប្រាប់ពេលរាយការណ៍ហ្នឹងគាត់ដឹងដែរតើហី??

ខ៖គាត់មិនមែនថាមិនដឹង តែគ្រាន់តែដឹង តែមិនដឹងថាគេចទៅណារួច វាមិនរួចកាលហ្នឹង!!

ក៖រត់អត់កើតម៉ងពូហោ?

ខ៖ហ៊ឺសម័យហ្នឹងគេថាគុកអត់ជញ្ជាំង អ្នកគ្រូវឯងដឹងស្រាប់ហើយគុកអត់ជញ្ជាំងទៅតាមណា??

ក៖អាមួយ !!ពិបាកនិយាយណាស់ពូណោះ?ទៅណាគឺមានទ័ពប៉ុល ពតហ្នឹងនៅហ្នឹងម៉ងពូហោ?

ខ៖វានៅគ្រប់កន្លែងហ្នឹងហើយ យើងមិនចេញ គ្រាន់តែថា ថាអញ្ចេកថាឧទាហរណ៍យើងនៅឧទាហរណ៍ថាខ្ញុំនៅភូមិកោះគរអញ្ចឹង ហើយនឹងភូមិព្រៃកថីនៅជាប់គ្នាអញ្ចឹងហ៊ិ!!តែឆ្លងភូមិនេះចូលក្នុងភូមិនោះក៏ឆ្លងអត់បានដែរ!!ភូមិណានៅភូមិនៅ ឆ្លងអត់បានទេ ឆ្លងកាត់អត់បានទេ

ក៖រត់ទៅនៅព្រៃអីអត់បានម៉ងពូហោ??

ខ៖ព្រៃណាបើនៅក្នុងព្រៃវាកាប់វាលគាស់រំលើងធ្វើស្រែធ្វើស្រូវយើងទៅនៅហ្នឹងព្រៃឯណា!!

ក៖ហ៊ឺ!!វេទនាណាស់ !ខ៖បាទ!!ក៖រត់ទៅស្រុកគេក៏មិនកើតទៀតហោ?

ខ៖ចេញណា ចេញទៅណារួច។

ក៖វាស្គាល់មុខអ្នកនៅក្នុងភូមិហ្នឹងហើយអស់ហើយពូហោ?

ខ៖អើរវាស្គាល់ បើគិតទៅអាអ្នកអាអ្នកវាដឹកនាំក្នុងភូមិគិតសុទ្ធតែប្រជាជនក្នុងភូមិតើយកធ្វើមេកងយកធ្វើអីណាទព័យកធ្វើអីវាមានកាំភ្លើងមានអីឆ្លបអីហ្នឹងសុទ្ធតែអាអ្នកក្នុងភូមិយើងហើយវាមិនស្គាល់យើង។

ក៖ហ៊ឺ!!សម្លាប់តាមពិតអ្នកក្នុងភូមិយើងហ្នឹងសម្លាប់តែគ្នាយើងហ្នឹងមែនទេពូ?

ខ៖បាទ!!មិនមែនប៉ុល ពតណាមកសម្លាប់ អត់ទេ។

ក៖តែគ្នាឯងហ្នឹង?

ខ៖បាទ!!!

ក៖អូយឆ្កួតសុទ្ធម៉េចទេពូ មនុស្សជំនាន់ហ្នឹងញ៉ុមអត់យល់សោះ អ្នកនៅតែស្លូតស្លូតអ្នកដែលអាក្រក់អាក្រក់!!ខ៖បាទ!!ក៖ពូអ្នកដែលធ្វើអាពតហ្នឹងមានអ្នកដែលស្លូតៗពីដំបូងហើយបានទៅអញ្ចឹងអត់?

ខ៖ពីដំបូងមានស្លូតដែរហ្នឹង តែដល់មើលទៅស្លូតហ្នឹងដូចថាខ្ញុំស្រលាញ់អាអ្នកស្លូត២ ៣នាក់ដល់គេថាអាស្លូតហ្នឹងមើលទៅអត់មានបាត់មនុស្សបង់មនុស្សអីចឹងដកអាហ្នឹងចេញទៅដាក់អាអ្នកកាចមកវិញអាហ្នឹងអញ្ចឹងតើ!!ក៖អូយ!!ខ៖អាអ្នកស្លូតដូចថាវាអត់មានរីកចំរើនរបស់វាហ្នឹងហាំ!!

ក៖រីកចំរើនគឺសម្លាប់មនុស្សហ្នឹងម៉ងហេ?ខ៖បាទ!!ក៖អានេះអាក្រក់ណាស់ !!ខ៖បាទ!!ក៖ពូម៉េចដែរបានផុតពីជំនាន់អាពតម៉េចដែរមួយៗបងប្អូនអីវ៉ាន់ទាំងអស់គ្នាហ្នឹង?

ខ៖វាផុតអាពីប៉ុល ពតហ្នឹងមក អើរផុតពេលប៉ុល ពតហ្នឹងមកវាអារម្មណ៍វាសប្បាយវាដូចថាចង់និយាយថាម្នាក់ៗនិយាយថាឆ្អឹងដែកស្បែកស្ពាន់ ឆ្អឹងមាសអស់ហើយ ជីវិតមាសគ្រប់គ្នាទៅហ្នឹងហាំ!!

ក៖ហ្នឹងហើយ!!ខ៖បាទ!!ក៖ឆ្អឹងដែកស្បែកស្ពាន់ហ្នឹងមែនពូការងារសាហាវ ហូបមិនបានទៀត!!ខ៖បាទ!!ក៖ហ៊ឺយកទៅសម្លាប់ចោលទៀតបើហូបលួចហូបអីវ៉ាន់ហើយគេអញ្ចឹងហិ ឧទាហរណ៍បើគេផ្ទះយើងនៅអញ្ចឹងក្រោយផ្ទះយើងហ្នឹងមានដើមចេកមានខ្នោរ មានល្ហុតមានស្វាយអីចឹងហូបក៏អត់បានដែរ ហ៊ានតែយើងហូបរបស់របរយើងដាំសោះហូបមួយពីរអើ

ហ្នឹងវាថាយើងហូបក្បត់សម្ងហាភាព គេរាយប្រាប់មិត្តបងគេយកយើងទៅហើយអញ្ចឹងហាំ!!កៈហុឺ!!ខៈអារបស់របស់យើងសោះ វាដូចថាក្បត់សម្ងហាភាពវា!!

កៈអ្វីទាំងអស់គឺត្រូវតែរូម?

ខៈបាទ!!

កៈហេបងនេះ!!អ៊ិចឹងពូពេលបែកជំនាន់ប៉ុល ពតមកលោកពូធ្វើទាហានមែនទេលោកពូ?

ខៈញ៉ុមធ្វើទាហាន ។

កៈគេចាប់ឬមួយក៏អី?

ខៈអើរកាលហ្នឹងគេបើយើង គេមិនចាប់ក៏ដូចចាប់ដែរគេ យើងនៅផ្ទះអត់បាន!!កៈហុឺៗ!!ខៈត្រូវតែធ្វើទាហានអ៊ីចឹងហើយ ដល់អញ្ចឹងញ៉ុមទៅចូលរត់ទៅធ្វើទាហាននៅអើរ នៅស្រុកតាខ្មៅនេះ ញ៉ុមអត់ចូលនៅយើងនេះទេ ញ៉ុមទៅចូលនៅតាខ្មៅហ្នូ!!

កៈម៉េចអ៊ីចឹងវិញពូ?

ខៈញ៉ុមអ់តចូលនៅនេះញ៉ុមអត់ចូល ញ៉ុមទៅចូលនៅតាខ្មៅ ចូលបានតែ១០ថ្ងៃ ចូលបាន១០ថ្ងៃអើរឥលូវនេះហ្នឹងនៅធ្វើមេឃុំរាល់ថ្ងៃអើរ យ៉ាវ ឡេងនៅធ្វើកំពង់សំណាញ់រាល់ថ្ងៃហ្នឹង!!

កៈញ៉ុមស្គាល់គាត់តើ!!កូនគាត់តើ!!

ខៈយ៉ាវ ឡេង យ៉ាវ ឡេងហ្នឹងមេញ៉ុមតើ!!ដំបូងហ្នឹងហា ហើយដល់នេះចូលបាន១០ថ្ងៃគេបញ្ជូនញ៉ុមទៅរៀនស្វាយ ទៅកន្លែងវ៉ីកវីុននៅរៀនស្វាយ !!កៈហុឺ!!ខៈដល់ចូលទៅរៀនស្វាយបានដេកបានតែមួយយប់ទេ គេបើខោអាវទាហានអោយ គេបញ្ជូនញ៉ុមទៅប៉ៃលិនម៉ង!!ញ៉ុមគ្រាន់តែឈរជើងប្រហែលនៅប៉ៃលិន៣ឆ្នាំ។

កៈចាញ់ទេពូ?

ខៈទៅតំបន់ហ្នឹងញ៉ុមដំបូងញ៉ុមចាញ់ជិត៣ខែថាអត់រស់ទេខ្ញុំសន្លប់ សន្លប់មួយអាទិត្យហាំ!!សន្លប់អត់ដឹងខ្លួន។កៈហុឺ!!ខៈវាគ្រុនចាញ់ គ្រុនចាញ់ខ្លាំងពេក។

កៈចាំអូយសាហាវណាស់ពូ!!

ខៈគ្រាន់តែដល់ពេលដឹងខ្លួនឡើងជើងដៃហ្នឹងចងជាប់គ្រែបន្ទោកសារ៉ូម អើរសារ៉ូមម្ខាង អើរម្ខាង៤ផ្លោកម្ខាង៤ផ្លោក។

កៈសាហាវម្ល៉េះ?

ខៈបាទគិតមើលបន្ទោកមួយអាទិត្យ!!

កៈអីចឹងពូតពីអាកន្លែងធ្វើទាហានហ្នឹងមកទៀត ពូម៉េចបានរួចមកផ្ទះវិញឈប់ធ្វើអាទាហានហ្នឹងទៀត?

ខៈញ៉ុមកាលហ្នឹងញ៉ុមមកពីទាហានវិញញ៉ុមទៅចូលឆ្នាំ៨៧(១៩៨៧)ហេញ៉ុមធ្វើទាហាន!! ហើយដល់នេះញ៉ុមមកវិញមកឆ្លងឆ្នាំ៨៩(១៩៨៩)ដល់នេះទាហានបាក់ទព័ប៉ៃលិនបាក់ទ័ពទាំងអស់ ប៉ៃលិនសាលាក្រៅអីហ្នឹង!!បាក់គ្រប់កន្លែងទាំងអស់ ដល់បាក់ ដល់នេះក៏នាំគ្នាមកជ្រួលមកដល់ មកដល់បាត់ដំបង បាត់ដំបងកាលហ្នឹងមកដល់ញ៉ុមចូលយកគេម្នាក់ត្រូវរបួសយកមកដេកពេទ្យបាត់ដំបងហ្នុំ!!កៈហ៊ើៗ!!ខៈដល់នេះរួចទៅបាក់ទ័ពទាំងអស់ រួចខ្ញុំយកទាហានហ្នឹងមកដេកពេទ្យហ្នឹងអើរអាហ្នឹងកាលហ្នឹងប្រធានគ ប្រធានគ ហើយបើប្រៀបធៀបមកឥឡូវនេះចូលសក្តិ សក្តិ២កន្លះសក្តិ៣ហើយណាស់!!កៈចា៎!!ខៈហើយខ្ញុំកាលហ្នឹងខ្ញុំក៏ប្រធានគដែរ។ដល់បានសម័យដល់បានមកដល់មានអាមិត្តភក្តិញ៉ុមមកមកក្រោយថាណៃហ្គែងកុំទៅវិញហា៎!!ហើយថី?ញ៉ុមបំរុងទៅវិញហើយ!!ថី?គេថាអោយតែឃើញឈ្មោះហ្គែងមុខហ្គែងគេចាប់ហ្គែងបាញ់ចោលហើយ!!កៈហ៊ុ!!ខៈថាញ៉ុមហ្នឹងនាំទ័ពរត់ តែតាមការពិតទ័ពរាប់ពាន់រាប់ម៉ឺននាក់បាក់ទ័ពមកទាំងអស់ទប់ជាមួយខ្មែរក្រហមអត់បានហ្នុំហើយដល់នេះថា ថាញ៉ុមនាំទ័ពរត់ ហើយអោយតែឃើញមុខញ៉ុមចាប់ញ៉ុមបាញ់ចោល។

កៈហើយធ្វើម៉េចដល់អញ្ចឹងទៅពូ?

ខៈដល់ញ៉ុមថាហា៎ដល់ថាចាប់បាញ់ចោល ដល់នេះហ៊ីតស៊ូយកមកអោយម៉ែអាណាទេ អញមិនមែនតស៊ូអោយម៉ែអញណាម៉ែឪអញងាប់អស់ហើយ ហើយអីចឹងអញមិនទៅអោយហ្គែងបាញ់អញចោលទេនឹកឃើញអីចឹងញ៉ុមរត់មកផ្ទះម៉ង!!រត់មកផ្ទះហ្នឹងក៏អត់មកចូលផ្ទះហ្នឹងដែរមកមានអាមិត្តភក្តិញ៉ុមមួយវានៅកំពង់ចាម វាទាហានថ្មីចាប់ទៅ វាអត់ស្គាល់ផ្លូវទៅអីណាអោយវាជូន វាអោយខ្ញុំជូនទៅកំពង់ចាមទៀត ដល់ទៅដល់ញ៉ុមឡើងជិះកប៉ាល់អាមុខវាំងនេះ អាកំពង់ចាមកាលហ្នឹងជិះកប៉ាល់មិនមែនឡានដូចឥឡូវទេ ជិះកប៉ាល់ទៅ២យប់ ២ថ្ងៃបានទៅដល់កំពង់ចាម!!កៈហ៊ើៗ!!ខៈដល់ទៅដល់គេណោះមានបងធំមានអីគេឃាត់នៅហ្នឹងអីហ្នឹងបាន

ជូនកូនគេឪគេម៉ែគេបានជូនកូនគេទៅឃាត់នៅហ្នឹង នៅកំពង់ចាមពផ្ទាំអត់មកស្រុកទៀត ដល់នេះ ដល់នៅកំពង់ចាមពឆ្នាំគិតថាមិនរកស៊ីអីទេហាំមិនដឹងរកស៊ីអី ដល់នេះស្រាប់គេ គេដូចថាគេរើសទាហានទៀតហាំហើយយើងអាចំនូលថ្មីយើងទៅនៅអញ្ចឹងនៅអត់ស្រួលនៅក្នុងស្រុកក្នុងទេសគេហាំ!!កះហ៊ឺ!!ខះដល់អញ្ចឹងស្មគ្រ័ចិត្តចូលធ្វើទាហានខេត្តកំពង់ចាមទៀតចូលធ្វើទាហានហ្នឹងចូលធ្វើទាហានស្រុកក្រូចឆ្មា!!កះចាំ!!ខះហើយដល់នេះបើគិតទៅមេ ដល់ចូលស្វាយចេកស្រុក គេថាល្បីណាស់ស្រុកស្វាយចេកយើងនៅទៅបន្ទាយមានជ័យហ្នឹង!!កះហ៊ុៗ!! ខះដល់ទៅនៅអើរនៅសង្គ្រាមនៅហ្នឹងដល់រួចទៅដល់យកទៅស្វាយចេក ម៉ៅ ភារុណ ចៅហ្វាយខេត្តកណ្ដាលយើងរាល់ថ្ងៃនេះហាំ!!កះហ៊ឺៗ!!ខះកាលហ្នឹងគាត់បញ្ជារការយោធាអើរខេត្តកំពង់ចាមតើ!! មេមេទព័ញ៉ុមហ្នឹងហាំ!!កះចាំ!!ខះម៉ោ ភារុណហ្នឹងហើយដល់ឥឡូវគេចៅហ្វាយខេត្ត!!កះហ៊ឺៗ!!ខះហើយដល់នេះទៅក៏ទៅទៀតស្មគ្រ័ចិត្តទៅទៀតដល់ទៅស្រុកក្រូចឆ្មារត់អស់រលីង អាមេមួយពាក់សក្តិ២រត់មកផ្ទះ ដល់គេថា ហ៊ឺមកផ្ទះតែមួយភ្លេតទេ ដល់មកផ្ទះមកបាត់លែងទៅដល់នេះជិត១០០នៅស្រុកក្រូចឆ្មា នៅសល់តែ៦នាក់ទេ។

កះម៉េចបានទាហានរវល់តែបាក់ទ័ពហ្នឹងលោកពូវាវ៉ៃអត់ឈ្នះម៉ងហោ?

ខះវាអត់ឈ្នះហើយណាមួយគ្រាប់ខ្មែរក្រហមបាញ់ខ្លាំងចូលខ្លាំងណាស់!!កះចាំ!!ខះគ្រាប់ខ្លាំងតិចថាយើងហ៊ានបាញ់ដាក់ទៅគេ៤ ៥គ្រាប់ ចាំមើលថ្ងៃហ្នឹងវាស់ល្ងាចហ្ន៎គ្រាប់ផ្លោងវាមកហើយវាស់ល្ងាចនៅតែក្នុងត្រង់សេទៅណាអត់រួចទេ!!!ដល់នេះក៏នៅសល់៦នាក់ នៅបានតស៊ូ៦នាក់ហ្នឹងបានមកមក!!

កះពូនៅក្នុងចំណោម៦នាក់ហ្នឹងដែរហោ?

ខះនៅក្នុងចំណោម៦នាក់ដល់មកវិញមកដល់មកគេជប់លៀងមកជប់លៀងនៅអាខេត្តកំពង់ចាមហ្នឹង យើងទព័ដែលនៅសល់ហ្នឹងហាំ??ញ៉ុមបានបណ្ណ័សរសើរហាំ!!!បានបណ្ណ័សរសើរនៅស្រុកក្រូចឆ្មារបានបណ្ណ័សរសើរតែខ្ញុំទេបានបណ្ណ័សរសើរ!!កះហ៊ឺៗ!!ខះហើយដល់នេះគេអោយខ្ញុំថា ដល់គេរាប់អានស្រុកក្រូចឆ្មារគេថាអាហ្នឹងគិតទៅស្រុកក្រូចឆ្មារហ្នឹង ឈ្មោះអីទេញ៉ុមភ្លេចបាត់ហើយ ហើយចៅហ្វាយស្រុកក្រូចឆ្មារហាំ!!អើរហៅញ៉ុមអាពួកម៉ាក់អាពួកម៉ាក់ហ្អែងទៅកុំទៅវិញហ្អែងចូលធ្វើការនៅស្រុកហ្នឹងហើយអញអោយហ្អែងកាន់ទព័បញ្ជារការស្រុកក្រូចឆ្មារ ញ៉ុមថាអញអត់ទេ អញដើរលេងអត់ទាន់អស់ចិត្តអត់ទាន់អស់សប្បាយ ហ៊ឺបើថ្ងៃណាហ្អែងចង់មកធ្វើហ្អែងចូលកន្លែងអញ គេប្រាប់ញ៉ុមអញ្ចឹងហាំ!! តែញ៉ុមអត់ទៅញ៉ុមខ្ជិលដល់រួចទៅខ្ញុំចេញពីហ្នឹងទៅនៅអើរនៅមានម៉ែធមិបងធមិនៅមានចាមមានអីនៅហ្នឹងដល់នេះ

ទៅទៅស្ទឹងត្រែងហាំ!! វាបបួលទៅស្ទឹងត្រែងទៅនឹងគេទៀត ថាចាមវាទៅចងឈើក្បូនឈើ ទំលាក់អាក្បូនឈើយកមកធ្វើផ្ទះយើងហ្នឹង រួចឈើទាំងមូលទាំងធំៗហ្នឹង ពីខេត្តស្ទឹងត្រែងមកហ្នឹងជាប់របងទំលាក់មកហ្នឹង ចាមថាទៅស៊ីឈ្នួលចង ចងឈើហុបហ្នឹងបានលុយថ្លៃណាស់!! មួយដើមនាំគ្នារមាលឈើហ្នឹងទំលាក់ទៅទឹកហើយមុជយកពីក្នុងទឹកមកចងដាក់ក្បូននោះក្នុងមួយដើមហ្នឹងកាលហ្នឹងលុយនៅថ្លៃចាយមួយកាក់ពីរកាក់មួយរៀលពីររៀលមួយដើម១៥០០!! ក៖ចំ!ខ៖ដល់មួយដើម១៥០០ទៅជាមួយចាមទៀត ទៅជាមួយចាមមុនដំបូងអត់ដឹងអីមុជទឹកជាមួយចាមជាមួយអីដល់យូរៗមានអាមេអាមេរក្ខដ្ឋានមេខ្មែរយើងហ្នឹងពីភ្នំពេញយើងទៅលែងអោយខ្ញុំលែងដឹងអញ្ចឹងលែងអោយខ្ញុំមុជទឹកជាមួយចាមអោយក្តោបក្តាប់ពួកចាមនៅហ្នឹង នៅត្រែកត្រអាលហ្នឹងដល់៣ ៤ ឆ្នាំខ្ញុំគ្រាន់តែដើរស្រុកគេហ្នឹងដល់៣ ៤ឆ្នាំ ដល់នេះបាត់ញ៉ុម នឹកឃើញអញពុះអានាបឬស្សី ពុះរនាបឬស្សី រនាបឬស្សីដល់ពេលដល់រនាបឬស្សីត្រង់ៗស្អាតៗណាស់ ពុះអោយឡើងត្រង់ផ្លឹងដូចបន្ទាត់អញ្ចឹង បានប្រហែលជា១០០បន្ទះអញយកមកផ្ទះអញយកមកផ្ទះអញ នឹកក្នុងចិត្តហើយថាអញធ្វើផ្ទះ ធ្វើផ្ទះគំរោងទេណាស់តែខ្លួនមួយដឹងអីទេគំរោងថាធ្វើផ្ទះដល់នេះគិត មកដល់មកមុខវាំងភ្នំពេញនេះអត់មានលុយចាយហេឬស្សីអញលក់ចោលហើយហា ឬស្សីពុះរនាបឡើងស្អាតថែសលក់ចោលម៉ងទៅណាស់ !!ក៖ហ៊ើៗ!!ខ៖លក់ចោល មកដល់ហ្នឹងហើយមេគេហៅទៅផ្ទះគេ ទៅផ្ទះគេនៅអាកន្លែងសន្ធរម៉ុក កន្លែងជិះនៅសាលារៀនសន្ធរម៉ុក ដល់ទៅ អញដូចនឹកផ្ទះអញចង់មកលេងផ្ទះហ៎!!នឹកឃើញអញ្ចឹងហាំ!!ក៖ហ៊ើៗ!!ខ៖ហើយមកមិនដឹងបងប្អូននៅឯណាណីទេ ចុះយើងដើរយូរហើយគិតទៅទៅប៉ៃលិន៣ហើយទៅកំពង់ចាម ហើយទៅក្រូច!!ទៅស្ទឹងត្រែងឡើង៣ ៤ឆ្នាំទៀតឡើង ៧ ៨ឆ្នាំហើយណាស់!!

ក៖ចាំ!!អញ្ចឹងអត់មានផ្តល់ដំណឹងអោយអ្នកផ្ទះទេអញ្ចឹង??

ខ៖អត់មានអោយដឹងម៉ង។

ក៖គេគិតថាស្លាប់បាត់ហើយមែនទេពូហី?

ខ៖អើរបងប្អូនគេថាស្លាប់មែនហ្នឹង ហើយដល់នេះ អត់មានអោយដឹងម៉ង ដល់នេះញ៉ុមនឹកឃើញផ្ទះអញចង់ទៅលេងផ្ទះណាស់ប្រាប់មេនៅភ្នំពេញថាហ៊ីគិតទៅលេងផ្ទះបន្តិច ទៅក៏ទៅទៅទៅ ទៅដល់នេះមក មកដល់នេះមានអាអ្នកស្រុកមួយគេរត់ម៉ូតូឌុបគេស្គាល់ញ៉ុម ចុះបែកពីវានៅតូចៗហើយដល់គេគេមករត់ម៉ូតូឌុបគេមានប្រពន្ធមានកូនគេ ដល់គេហាបង!! គេចាំមុខញ៉ុមហាំ!! បងបងឯងទៅផ្ទះអត់?អញទៅតើ!!ហើយឆ្លើយជាមួយគេឆ្លើយព្រៀវទេ អត់ដឹងថា

អាណាគេទេហ៎ា!!ក:ហ៊ីៗ!!ខ:ហ្អែងនៅឯណា?ហេបងឯងទៅញ៉ុមជូនដល់ផ្ទះ អើរទៅដល់ផ្ទះបងរបស់បងបងឯងម៉ង ហ្អែងកូនអាណាគេហ៎ា??ចុះយើងដើរយូរហើយយើងភ្លាចសួរគេ កូនណា គេប្រាប់គេម៉ែឪវាឈ្មោះនេះហើយប្រពន្ធវា ញ៉ុមកូននេះៗអីទៅប្រាប់បានជូន ជូនមកដល់ផ្ទះហើយក្មួយញ៉ុមនេះ!មកដល់វាទូចមួយ វាទូចមួយអត់ស្គាល់ម៉ែគេធ្វើស្រូវ ធ្វើស្រូវធ្វើអង្ករ គេរត់ទៅតាម ម៉ែម៉ែថាបងប្អូនម៉ែឯងមកហ្ន៎!!មកមកតាមមកប្អូន !!ហើយមកញ៉ុមមានស្គាល់ក្មួយឯណា កាលញ៉ុមទៅវាទូចមួយហ្នឹង ញ៉ុមភ្លេច មកវាប្រហែលអាយុ៧ ៨ឆ្នាំហ្នឹងហ៎ា!!ក:ហ៊ី!!ខ:ស្រាប់ថាដល់នេះបងប្អូនម៉ែឯងមកហ្ន៎!!មកមកហើយ អាណាគេបងប្អូនអញ ថាត្រូវបងប្អូនម៉ែឯងថាអញ្ចឹង ហើយដល់មកមក គេឃើញញ៉ុម អូហ្អែងអញថាងាប់បាត់ហើយថាគេអោបខ្ញុំយំអោបអីគ្រប់គ្នា!!ក:ហ៊ី!!ខ:ដល់មកបានប៉ុន្មានយប់ញ៉ុមថាញ៉ុមអត់នៅទេញ៉ុមទៅវិញទៅវិញហ៎ា!!ក:ហ៊ីៗ!!ខ:ដល់ញ៉ុមទៅវិញទៀត។

ក:ទៅកំពង់ចាមវិញទៀត?

ខ:អើរទៅ ទៅកំពង់ចាម ហាមិនមែនទៅកំពង់ចាមទេហាញ៉ុមទៅស្ទឹងត្រែង ញ៉ុមទៅស្ទឹងត្រែងទៅញ៉ុមទៅកាន់កាប់ដេប៉ូឈើនៅស្ទឹងត្រែងទៀត!!ក:ចា៎!!ខ:ដល់ទៅទៀតទៅបានមួយឆ្នាំបានថាមក សារក្រោមមកលេងមកលេងឪពុកធំហាម្តាយធំញ៉ុមឥឡូវគាត់ទៅអាមេរិកហើយម្តាយធំគាត់ឥឡូវគាត់ស្លាប់ហើយនៅតែឪពុកធំទេ!!ឪពុកធំព្រះជន្មគាត់ចូល១០០ហើយឥឡូវហ្នឹងហ្ន៎!!

ក:ចំហើយតែអត់ទាន់ស្លាប់?ខ:នៅ!ក:ចំ!!

ខ:ស្លាប់យាយមុន យាយទឹម៨០ជាង ហើយដល់នេះក៏គាត់ថាដឹងគាត់និយាយបញ្ចុះបញ្ចូលម៉េចទេ!!!និយាយមិនអោយទៅវិញម៉ងហ៎ា!!ក:ហ៊ីៗ!!ខ:អញ្ចេះមួយអញ្ចេះពីរហ្អែងកុំទៅវិញហ្អែងនៅហ្នឹងហើយ ហ្អែងតែទៅវិញយកខ្មោចចោលអើរឆ្អឹងចោលស្រុកគេហើយគាត់ចេះតែថាទៅណាស់!!!ហើយដល់ថាអញ្ចឹង ដល់នេះញ៉ុមថាអត់ទេនៅហើយបងហ្អែងហិបងហ្អែនៅបារាំងផ្ញើរលុយទុកអោយហ្អែងហិ!!

ក:បោកទេពូហី?

ខ:អត់បោកទេមែនទែន។

ក:មែនទែន!!

ខ៖គាត់ធ្វើទុកអោយ៥ជីកន្លះ!!ក៖ហ្ហ៎!!ខ៖ទុកអោយមែនអញ្ចេះមួយអញ្ចេះពីរដល់ថាទុកអោយ ហ្អែងនៅធ្វើរកស៊ីរកអីនៅហ្នឹងហើយ។ក៖ចា៎!!ខ៖ដល់នេះបើបងធំបងគេបង្អស់ដឹងឯងមាន លុយបបួលឯងទិញម៉ាស៊ីនបូមទឹកអោយឯងនៅ។

ក៖អត់បានទៅទៅ?

ខ៖អត់បានទៅ ឮគេថាធ្វើនៅនេះរកលុយបានខ្លាំងអីអញ្ចឹងក៏ទិញម៉ាស៊ីនទឹកលុយរបស់យើង ទាំងអស់ ដល់ទិញទៅម្ដាយធំញ៉ុមឪពុកធំហ្នឹងហើយនឹងយាយខ្ញុំហ្នឹងខាងប្រពន្ធញ៉ុមនេះ គាត់ មិត្តភក្តិគាត់គាត់ទាក់ទងគ្នាគាត់ម៉េចគាត់ចូលទំនាក់ទំនងចូលស្ដីគាត់នេះ!!ហើយហ្អែងត្រូវតែ យកហា៎!!ញ៉ុមថាញ៉ុមអត់យកទេហើយហ្អែងដែលឃើញគេនៅ?ញ៉ុមថាអត់ទេ ញ៉ុមធ្លាប់តែ ឃើញគេនៅពីក្មេងនៅពីទូចហា៎!!នៅប៉ុនអាទូចញ៉ុមនេះអើរគាត់ទៅទូលកញ្ជើរបាយយកទៅ ស្ទូងស្រូវឃើញ ឃើញដល់ធំញ៉ុមដែលឃើញអី ឃើញតែទៅរៀននៅសាលាសិត្សហ្នឹង!!ក៖ ហ៊ឺៗ!!ខ៖ដឹងតែគាត់ទៅអញ្ចឹងតែមិនដែលថាដែលតែឃើញគាត់ ឃើញគាត់គាត់មិនដែលស្ដី ដែលនិយាយ មិនដែលហ៊ាននិយាយរកគាត់ទេ ដល់នឹកឃើញអត់មានថាស្រលាញ់គាត់ទេ កាល់ហ្នឹង!!ក៖ចា៎!!ខ៖ហើយដល់នេះចាស់ៗហ្នឹងគាត់ចេះតែទំនាក់ទំនងនឹងគ្នាគាត់ទៅ ហើយ យាយណោះហើយនឹងម្ដាយធំញ៉ុមឪពូកធំញ៉ុមហ្នឹងគាត់ចេះតែដន្លងលិចដន្លងកើតគាត់ចេះ តែដន្លងទំនាក់ទំនងគាត់ ហើយគាត់ថាហ៊ីបើថានេះដន្លងញ៉ុមអោយចាប់អោយខ្ញុំធ្វើកូនប្រសារ កូនអីអញ្ចឹងទៅណាស់!!ក៖ចា!!ខ៖ដល់នេះបញ្ចុះបញ្ចូលញ៉ុមអោយញ៉ុមយក ញ៉ុមថាអត់យក ទេក្នុងស្រុកភូមិ ញ៉ុមថាអត់យកទេ!!ហ្អែងត្រូវតែយក តែមិនយក ហ្អែងយកឆ្អឹងចោលស្រុកគេ ហើយ។

ក៖ហើយពេលហ្នឹងពូរៀបការពេលហ្នឹងអាយុប៉ុន្មានវិញពេលហ្នឹង ?

ខ៖អង្កាល់ញ៉ុមការជាមួយគាត់ញ៉ុមការអាយុ៣៣ហើយ។

ក៖អូយ ពូដើរពេកនោះ!!

ខ៖ដើរពេក!!

ក៖តែពេលហ្នឹង តែពេលដើរហ្នឹងអត់មានប្រពន្ធអត់មានអីណាហី?

ខ៖អត់ទេ!!មានគេចង់លើកកូនក្រមុំអោយដែរតែញ៉ុមអត់យក ញ៉ុមនឹកឃើញថាអញ្ចកកាល ហ្នឹង ជំនាន់ហ្នឹងញ៉ុមនៅធ្វើទាហានយើងនឹកឃើញថាហ៊ីញ៉ុមនិយាយដូចថាអ្នកខ្លះ គេនឹក

ឃើញអញ្ចឹងគេចេះយកបានហើយណាស់ ដូចថាមានម៉ែធមិកូនក្រមុំស្អាតៗលក់គុយទាវលក់កាហ្វេអីចឹងទៅណាស់!!ចេះតែលើកកូនអោយញ៉ុមដែរ តែញ៉ុមថាញ៉ុមអត់យកទេ តែបើស្រុកបាត់ដំបងបងសក្តិយើងទាហានគេចូលចិត្តលើកកូនអោយណាស់!! តែញ៉ុមញ៉ុមអត់យកញ៉ុមនឹកឃើញថាខ្ញុំធ្វើទាហានបើខ្ញុំយកទៅលោរគ្នាមានកូន ហើយយើងធ្វើទាហានលោរឡើងសមរភូមិទៅងាប់ទៅគ្នាមេម៉ាយ ហើយងាប់ទៅអ្នកណាចិញ្ចឹមកូនយើងនឹកឃើញវែងឆ្ងាយអញ្ចឹងបានញ៉ុមអត់យកញ៉ុមនិយាយតាមការពិតអីចឹងតាមត្រង់ម៉ង!!

ក៖ចា៎!!អីចឹងដល់ពេលចូលស្ដីដណ្ដឹងពូយល់ព្រមការជាមួយទៅ?

ខ៖អើរព្រមការតែដល់នេះ ញ៉ុមក៏ថាគាត់ថាហ្អែងត្រូវតែយកអញ្ចឹងព្រោះគាត់នេះចូលអញ្ចឹងហើយញ៉ុមថាដល់គាត់និយាយអិចឹហាអំឯងធ្វើម៉េចស្រួលធ្វើទៅ!!អើរបើហ្អែងថាធ្វើម៉េចស្រួលធ្វើទៅអីចឹងស្រេចតែអញ អីចឹងហ្អែងចាំតែរៀបចំខ្លួនទៅ!!

ក៖ចា៎អោយជំនូនគេពេលហ្នឹងប៉ុន្មានដែរពូពេលហ្នឹង?

ខ៖កាលពេលហ្នឹងដែរលលុយកាក់ជូនកាលហ្នឹងគឺលុយរបស់ខ្ញុំទេ!!ក៖ហ៊ឺ!!ខ៖គ្រាន់តែបងប្អូនម៉ែឪម្ដាយធំឪពុកធំគាត់គ្រាន់តែមានគំនិតទេណាស់!!លុយកាក់លើខ្ញុំគាត់ទារកាលហ្នឹងថ្លៃផ្ទះគាត់ទារ២ជីៗក៖ចា៎!!ខ៖២ជីហើយដល់នេះដល់នេះសុំតវ៉ាថា១ជីកន្លះ ១ជីកន្លះហើយនៅខាងញ៉ុមការទាំងអស់ ការទាំងអស់ៗ

ក៖ហ្នឹងហើយពូមីងប្រាប់ដែរ!!

ខ៖បាទ!!ហើយដល់ណោះពូសូរមួយជីកន្លះក៏មួយជីកន្លះទៅ គាត់ក៏ព្រមយកមួយជីកន្លះហ្នឹងការនៅខាងញ៉ុមទាំងអស់ហ្នឹង!!ហើយដល់នេះ កាលហ្នឹងមួយជីកន្លះកាលហ្នឹងក៏វាមិនច្រើនដែរ!!ក៖ហ៊ឺៗ!!ខ៖មួយជីតែ៥០០០០លុយខ្មែរហ្នឹង មួយជីកន្លះមានទៅប៉ុន្មានៗ

ក៖ហ្ហ៎អិចឹង១៥០០០០ហ្នឹងមួយជីកន្លះ!!

ខ៖បានអីបាន១៥០០០០!!

ក៖ហ៊ឺ!!

ខ៖មិនបានដល់១០០០០០ផងហ្នឹងៗ

ក៖៧៥០០០។

ខ៖អើរបានតែ៧៥០០០ហ្នឹង បាទ!!ក៖ចាំ!!ខ៖បានតែប៉ុណ្ណឹងហ្នឹងគ្មានបានស្អី!!

ក៖ហើយពូម៉េចបានឈប់ធ្វើទាហានមក?អត់មានទៅ ការហើយអត់មានទៅធ្វើទាហានវិញទេហី?

ខ៖ទៅណា ដូចខ្ញុំនិយាយខាងដើមមិញអញ្ចឹងឃើញមុខញ៉ុមចាប់បាញ់ចោលហ្នឹង!!ក៖ហ្ន៎!!ខ៖អីចឹងញ៉ុមទៅទៅអោយគេបាញ់ចោលហ្នឹងធ្វើអីបើតស៊ូយូរណាស់ហើយហ្នឹង!!ក៖ហ៊ើៗ!!ខ៖ហើយបានដល់កាលហ្នឹងបានញ៉ុមរត់ដល់ធ្លាយដល់ណោះ អ្នកគ្រូឯងដឹងម៉េចទេដែលមេបញ្ជារការញ៉ុមអាមួយនៅដែលស្អីទៅហួសពីព្រែកហូរទៅបន្តិចទៅនេះ!!

ក៖ព្រែកកំពឹស!!

ខ៖បាទបាទនៅម្តុំហ្នឹងមេបញ្ជារការនៅហ្នឹងមួយ ហ្នឹងឈ្មោះវា ឈ្មោះអាភាមិនដឹងស្អីភាទេនៅហ្នឹងមួយហើយមកនៅណោះ គៀនស្វាយបញ្ជារការយោធានៅ ប្រធាននយោបាយយោធាឈ្មោះអ៊្វ យ៉ាត។ក៖ចាំ!!ខ៖ឈ្មោះអ៊្វយ៉ាត!!ហើយខេត្តតាកែវ ពេជ្រ សុខន មេបញ្ជារការ អញទៅណាទេ មេនៅនេះជិតៗអីចឹងគេចទៅកំពង់ចាម ស្ទឹងត្រែងនោះម៉ងទៅ!!

ក៖ខ្លាចគេស្គាល់មុខពូណោះ?

ខ៖បាទខ្លាចគេស្គាល់មុខ។

ក៖តែទៅកំពង់ចាមពូថាពួកម៉ាក់ថាបើនេះពូព្រមត្រលប់ទៅវិញដើម្បីមានគាត់អញ្ចឹងទៅដើម្បីអោយគាត់អោយជួយមានការងារអីធ្វើហ្ន៎??

ខ៖តែញ៉ុមនឹកឃើញថា ដូចញ៉ុមដើរវាឆ្អែតហើយញ៉ុមខ្ជិលម៉ងទៅ!!

ក៖ឈប់ម៉ងទៅ?

ខ៖បាទ!!

ក៖ចាំហ្នឹងហើយ អីចឹងពូបន្ទាប់ពីរៀបការជាមួយអ្នកមីងមកតើលោកពូមានកូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខៈតែការមក ឥឡូវកាត់ត្រួសៗកុំវែងពេកអ៊ីចឹង កូនប្រុសស្រីវាមាន៤នាក់ មាន៤នាក់ ស្រី២ ប្រុស២។

កៈចាំល្អទៀត!!!ខៈបាទ!!កៈឈ្មោះអីគេដែរពូតាំងពីបងគេរហូតដល់ពៅគេហា?

ខៈត្រកូលគេដាក់ត្រកូលម៉ិញទាំងអស់។កៈចាំ!!ខៈម៉ិញ ផល្លា ម៉ិញ សេង ថៃ ម៉ិញ សុរិយា ម៉ែ រតនា។

កៈចាំឈ្មោះពីរោះៗទៀតអ៊ីចឹង!!ខៈបាទ!!កៈអ៊ីចឹងពូអោយគាត់បានទៅរៀនទាំងអស់គ្នាមែន ពូ?

ខៈបាទ បានរៀនទាំងអស់ បងបើកុំវាឈឺនោះកុំអីវាបានថ្នាក់ខ្ពង់ខ្ពស់ដែរ។

កៈចាំលោកពូគិតថាការសិក្សាមានតំលៃម៉េចដែរសំរាប់ជីវិតបានជាពូអោយគាត់បានទៅ សិក្សាគ្រប់ៗគ្នា?

ខៈញ៉ុមនឹកឃើញថាអញ្ចេះការសិក្សាបានញ៉ុមអោយវាសំរាក សំខាន់នោះដោយសារថាយើង ម៉ែឪយើងអត់មានអីអោយទ្រព្យសម្បត្តិអីចែកអោយវាទេគឺមានតែចំនេះវិជ្ជាការសិក្សាហ្នឹង ហើយដែលចែកអោយវា ដែលសំពាយទ្រព្យសម្បត្តិរបស់វាគឺចោរមិនអាចប្លន់បានទេ ការ សិក្សាញ៉ុមចង់ថាអញ្ចឹង។កៈចាំ!!ខៈបើយើងមានចំនេះចេះដឹងខ្ពង់ខ្ពស់អញ្ចឹងបាននិយាយថា យ៉ាងហោចណាស់យើងធ្វើគ្រូបង្រៀនក៏ខ្លាំងដែរ គ្រាន់តែគ្រូបង្រៀនឥឡូវគ្រូបង្រៀនតែមួយ ពេលទេ ប្រាក់ខែគ្រូក្នុងមួយខែ១០០០០០០ ហើយបើបង្រៀនព្រឹកល្ងាចមួយខែ២០០០០០០ គ្រូបង្រៀនគ្រូ អញ្ចឹងបានថាយើងចំនេះវិជ្ជាត្រឹមធ្វើគ្រូបង្រៀនក៏យើងអាចចិញ្ចឹមជីវិតយើងបាន ដែរ។កៈហ៊ឹៗ!!ខៈញ៉ុមនឹកឃើញអញ្ចឹងៗ អញ្ចឹងបានថាបណ្តុះបណ្តាលអោយកូនខំប្រឹងរៀន ហ្នឹងគឺជាជាសំពាយទ្រព្យសម្បត្តិរបស់យើងហើយ។

កៈហ្នឹងហើយ ល្អមែនទែនពូ!!ខៈបាទ!!កៈពូមានចង់និយាយអីបន្ថែមទៀតអំពីជីវិត អត់មានចាំ អីដែលបំភ្លេចមិនបាននៅក្នុងជីវិតអីអត់?

ខៈអើរអារឿងជីវិតបំភ្លេចមិនបាន មិនបាច់និយាយទេ បើនិយាយវាប៉ះពាល់ច្រើនញ៉ុមមិនបាច់ និយាយទេ!!

កៈម៉េចទៅ និយាយមកពូនិយាយមកអត់អីទេ!!

ខ៖មិនបាច់និយាយទេ។ចង់និយាយពីជីវិតប៉ះពាល់មិនចង់និយាយទេ រឿងថាអារឿងប្រទេសជាតិបាត់ទឹកបាត់ដីហ្នឹង បានបានញ៉ុមមិនចង់និយាយ ខ្ជិលនិយាយ។ក៖ហ្ន៎!!ខ៖ញ៉ុមនៅស្តាយអាហ្នឹងបានថាខ្ញុំរៀនខ្ញុំដឹងប្រវត្តិអើរសាស្រ្តដីខ្មែរដល់ត្រឹមណាត្រឹមណា!ក៖ចា៎!!ខ៖តែខ្ញុំអត់អាចនិយាយទេ!!អាហ្នឹងប៉ះពាល់ដល់គេ ។

ក៖ចា៎អ៊ីចឹងអត់អីទេពូមួយហ្នឹងប្រហែលជាក្មេងៗខាងក្រៅគាត់អាចស្រាវជ្រាវបានដឹងថាដោយសារនិយាយទៅប្រវត្តិប្រទេសខ្មែរមួយៗភាគច្រើនគេដឹងច្រើនប៉ុន្តែពេលខ្លះអត់ដឹងស៊ីជំរៅទេដល់អ្នកដែលខាងហ្នឹងម៉ងអីវ៉ាន់។

ខ៖បើជំនាន់ខ្ញុំរៀនអាខាងអ៊ីចឹងគ្រូគេបង្រៀនទាំងអស់។

ក៖ដល់អស់ម៉ងពូហោ?

ខ៖បាទដល់អស់ម៉ង។

ក៖ឥឡូវពូនិយាយពីនេះវិញម្តងនិយាយពីគ្រូបង្រៀនមកមិនមែនជានេះរបស់ពូដែលអ្វីដែលគ្រូបង្រៀន តើគាត់បង្រៀនថាម៉េចដែរ?

ខ៖គាត់រៀនគាត់បង្រៀនថាអក្សរសាស្រ្តខ្មែរ ពង្សប្រវត្តិសាស្រ្តខ្មែរដីខ្មែរទឹកដីខ្មែរមានផ្ទៃក្រឡាប៉ុន្មានអ៊ីចឹងប្រាប់ដឹងទាំងអស់តើ!!ក៖ហ៊ឺៗ!!ខ៖ដីខ្មែរប្រវត្តិសាស្រ្តយើងពង្សប្រវត្តិសាស្រ្តទីមួយដំបូងបំផុតមានដល់ផ្ទៃក្រឡាមានដល់១៩១ពាន់គីឡូម៉ែត្រក្រឡា។

ក៖វាលាតទៅដល់ចិនមែនទេពូ?

ខ៖វាគេហៅឥណ្ឌូចិន ឥណ្ឌូចិន ចុះពីចិនមកគឺខ្មែរតែម្តង។

ក៖ហ្នឹងហើយ។

ខ៖បាទ ហើយដល់មកដល់មកដល់អើរមួយជំនាក់កាលមួយទៀតប្រវត្តិសាស្រ្តខ្មែរនៅនៅសល់តែ១៣១ ០៣៥ក្រឡាម៉ែត្រការេ។

ក៖ហ្នឹងហើយ ០៣៥គីឡូម៉ែត្រការេ។

ខ៖ហើយដល់មកដល់ឥឡូវនេះនៅឮសូវត្រឹមតែ១០០ពាន់ទេ។

កៈហ៉ាអ៊ីចឹងចុះទៀតហើយអ៊ិចឹង?

ខៈបាទនៅសល់តែ១០០ពាន់ទេគេផ្សាយថ្ងៃមុនផែនទីមានតែ១០០ពាន់ទេ!!កៈចំ!!ខៈគេថា គេថាដីខ្មែរបាត់ណាស់ ដីខ្មែរមាន១០០ពាន់គឺវាស់ផែនទីគេត្រឹមត្រូវគេថាអ៊ីចឹង ដល់យើងអ៊ីចឹងបានថាយើងមិនអាចនិយាយបាន។

កៈពូអើយពូក៏ម្លេះ!!!សាហាវណាស់!!

ខៈអ៊ីចឹងបានថាអារឿងហ្នឹងបានថាញ៉ុមនិយាយ និយាយអត់កើតញ៉ុមអត់និយាយ។

កៈតាមពិតភាគច្រើនប្រជាជនមួយៗណាស់គេដឹងទាំងអស់ហ្នឹងតែគ្រាន់តែថាអ្នកណាគេរើរ!!

ខៈអ្នកហ្នឹងបាត់ខ្លួន។

កៈហ្នឹងហើយ អើយយ៉ាប់ម៉ងពូ!!

ខៈបាទបាទ!!

កៈអ៊ីចឹងពូឥឡូវសំរាប់ឥលូវជីវិតរបស់ពូរាល់ថ្ងៃពូប្រកបរបរអីចិញ្ចឹមជីវិតកូនចៅប្រពន្ធអីវ៉ាន់ដែរ?

ខៈឥឡូវនេះបើគិតទៅខ្ញុំអត់មានអាចធ្វើអីគេកើតព្រោះថាដូចថាយើងវាចាស់ជ្រុលវាមិនអាចរកអីបានដូចថាដាំផ្ទីនាយអាយកំប៉ិកំប៉ុងអ៊ីចឹងយកមកហូបអាងសង្ឃឹមប្រពន្ធហើយនឹងកូនធ្វើការរោងចក្រហ្នឹងទៅកម្មករស៊ីឈ្នួលគេអាដាំផ្ទីហ្នឹងបើដាំអញ្ចឹងទៅបើដាំបើសិនណាមានពេលទំនេរអត់ដាំផ្ទី មានគេជួលធ្វើអីមានរែកដីត្រូវផ្លាក់ដីអីក៏ធ្វើអត់មានថាវារែកហើយថាហ្ន៎ថាឥឡូវត្រូវធ្វើអីត្រូវត្រួសស្មៅធ្វើអីមិនបាច់ថាស្អីទេ ធ្វើអោយអស់ម៉ង គេជួលរែកអាចមន៍ជីបង្គន់អោយចាក់ដំនាំគេរែកទៀត។

កៈហ៊ឺៗ!!ពូអត់ប្រកាន់។

ខៈអោយតែថាវាស្របច្បាប់កុំអោយតែយើងទៅប្លន់គេធ្វើអញ្ចឹង។

កៈចាំល្អណាស់អ៊ីចឹង។អ៊ីចឹងពូមួយនេះគឺជាសំនួរចុងក្រោយដោយសារញ៉ុមចាប់អារម្មណ៍នូវអ្វីដែលពូបានប្រាប់ពីជីវិតដូចវាបានក្បោះក្បាយច្រើនណាស់ពូ!!បើសិនជាចង់និយាយអីទៀតក៏បានដែរ អត់ទេពូហេ??

ខៈហេមិននិយាយអីទៀតទេព្រោះថានិយាយទៅដូចថាពេលវានិយាយទៅដូចថាខាងដើមញ៉ុមប្រាប់ដូចម៉េចហ្នឹងអ៊ីចឹង និយាយហ្នឹងអ៊ីចឹងវាប៉ះពាល់គេវាអត់និយាយទេអាហ្នឹង។

កៈចាំ អ៊ីចឹងពូសំនួរមួយចុងក្រោយតើពូមានពាក្យពេចន៍អីចង់ផ្ដែផ្ដាំទៅកាន់កូនចៅជំនាន់ក្រោយដែរអ៊ីចឹងហាំ??

ខៈសំនួរចុងក្រោយផ្ដែផ្ដាំទៅកាន់កូនចៅជំនាន់ក្រោយថាគ្រាន់ថាអារឿងដូចដែរខ្ញុំនិយាយអារឿងអើរប៉ះពាល់គេញ៉ុមអត់និយាយទេញ៉ុមគ្រាន់តែផ្ដាំថាកូនចៅជំនាន់ក្រោយអោយវាខំប្រឹងរៀនសូត្រ ចំនេះវិជ្ជាជាទ្រព្យសម្បត្តិរបស់យើងមិនអាចអ្នកណាមកប្លន់បានទេចំនេះវិជ្ជាជាសំពាយបុណ្យនិងសម្បត្តិរបស់យើងមិនអាចអ្នកណាប្លន់យកបានទេ!កៈហ៊ឺៗ!!ខៈអាហ្នឹងញ៉ុមគ្រាន់តែផ្ដាំផ្ញើរប៉ុណ្ណឹងតែគ្រាន់តែរឿងអីទៀតញ៉ុមអត់និយាយទេ!!កៈចាំ!!ខៈបាទ!!

កៈចុះសំរាប់អីដែលពូចង់អោយគាត់ជៀសផុត?ជៀសផុតពីអីគេដែរ?

ខៈជៀសផុតរាល់តែថ្ងៃគឺគិតទៅគឺអោយវាជៀសផុតពីគ្រឿងញៀន គ្រឿងញៀនហើយនឹងអើរមិត្តភក្តិប៊ិនភឿនដែលដើរផ្លូវអាក្រក់ហ្នឹងមិនអោយដើរតាមទេ!!កៈហ៊ឺៗ!!ខៈបាទ!!

កៈហ្នឹងហើយអោយគេចផុតពីទាំងអស់ហ្នឹង!!

ខៈបាទនឹងដើរតាមព្រះហើយនឹងអោយព្រះហ្នឹងជួយតំរង់ផ្លូវពួកវាផង។កៈចាំ!!ខៈហើយកូនញ៉ុមញ៉ុមនិយាយថាម៉េចទេតាមតែការពិតត្រង់ដែលដំបូងដែលញ៉ុមទៅថៃ ២ ៣ឆ្នាំ មកវិញកូនញ៉ុមចង់ចង់អត់ស្រួល ចង់របៀបចង់តាមគេតាមអីអត់ស្ដាប់មកទំរាំតែញ៉ុមពត់តំរង់វាបានវិញៈញ៉ុមថាចប់!!

កៈសេង ថៃហេ?

ខៈបាទ តែអាសេងថៃ ទាំងតូចទាំងធំទាំងអស់មកដល់ពត់ដំរង់ទំរាំតែបានញ៉ុមថាដំបូងញ៉ុមថាចប់បាត់ហើយ។

កៈហូពូ ពូទៅធ្វើការនៅថៃ៣ឆ្នាំមែនទេ?

ខៈបាទ!!៣ឆ្នាំ។

កៈពូធ្វើការនៅថៃពូធ្វើការអីគេវិញ?

ខៈញុំមទៅខាងសំណង់។

កៈម៉េចដែរពូពិបាកទេ?

ខៈហេធម្មតាយើងធ្វើខ្ញុំគេវាមិនដែរស្រួលទេ ។

កៈហើយគេអោយប្រាក់ខែម៉េចដែរពូនៅថៃ វាខុសពីខ្មែរម៉េចដែរ?

ខៈបើគិតជាមួយខ្មែរខុសមេឃហើយនឹងដីហ្នំនិយាយទៅ!!

កៈម៉េចវិញទៅពូ?

ខៈគ្រាន់ថាយើងដូចថាយើងធ្វើការនៅខ្មែរបើគិតជាថ្ងៃមួយថ្ងៃគេថា៣០០០០ គេថា៣០០០០ ថាថ្លៃ៩០០០០គេថាថ្លៃហើយបើនៅថៃវិញក្នុងមួយថ្ងៃធ្វើការ១១០បាត។

កៈហើយប៉ុន្មានទៅ?

ខៈមួយថ្ងៃ១១០បាតបើគិតទៅបើគិតទៅជាលុយខ្មែរយើងក៏វា៣០០០០ជាងដែរ។កៈចាំ!!ខៈ ៣០០០០ជាងតែវាមានលុយថែមម៉ោង លុយថែមម៉ោង បើគិតទៅបើគិតទាំងថែមម៉ោងផងក្នុងមួយថ្ងៃទាំងថែមម៉ោងហ្នឹងចូលបើគិតជាលុយខ្មែរមួយថ្ងៃហ្នឹង១០០០០០លុយខ្មែរ។

កៈហូ!!ខៈបាទ!!កៈចំទៅថែមម៉ោងបានសាហាវជាង

ខៈថែមម៉ោងគិតទៅអ្នកគ្រូវគិតអញ្ចេក មួយម៉ោង៥៨បាតអាហ្នឹងបើម៉ាក្នុងម៉ាថ្ងៃលុយថ្ងៃមួយថ្ងៃ១០០ ១២០ហា ៣២០អាហ្នឹងបានថែមម៉ោងក្នុងមួយម៉ោង៥៨បាតហើយក្នុងហ្នឹងក្នុងយប់ហ្នឹងយើងថែមជួនកាល៥ម៉ោង៦ម៉ោងអីអ្នកគ្រូឯងយកមើលមើល។

កៈហ្នំហ្នឹងហើយចឹអីចឹងបានបានច្រើនពូ!!ណេះ!!ខៈបាទ!!កៈពីបាកទេពូ?

ខ៖ការងារបើគិតទៅឈ្មោះជាសំនង់មែនតែវាអត់សូវពិបាកទេបានថាការងារក្រុមហ៊ុន ការងារក្រុមហ៊ុនដូចថាអ្នកគ្រូអីចឹង ដូចថាអ្នកគ្រូស្រីអញ្ចឹងក៏ដោយទៅធ្វើអញ្ចឹងក៏ដោយជាមួយប្រុសអីចឹងក៏ដោយគឺថាអត់មានអាណាប្រាក់ខែលើអាណាឡើយ គឺប៉ុន គ្នាទាំងអស់ស្រីក៏អញ្ចឹងដែរ។

ក៖ហ៊ីប្រទេសគេរៀបចំបានល្អណាស់ពូ!!

ខ៖គ្រាន់តែថាស្រីគ្រាន់តែថាយកអាអំបោសមកបោសអាកំតិចអាស៊ីម៉ង់ គ្រាន់តែស៊ីម៉ង់បោសហ្នឹងហើយការមួយម៉ោងកន្លះម៉ោងអង្គុយទៅបាត់ទៅណាស់ក៏៣២០ដូចគ្នាដែរហើយបើថាប្រុសថែមម៉ោងស្រីក៏ថែមម៉ោងដូចតែគ្នាហ្នឹង!!

ក៖ស្មើគ្នាទាំងអស់ហ្នឹងម៉ង??

ខ៖បាទ!!ស្មើគ្នាហើយជួនកាលគេអ្នកទៅ២នាក់ប្តីប្រពន្ធហាក្នុងមួយខែ មួយខែគេបានជិត៥០០០០បាតហើយហ្នូ!!ក្នុងមួយខែ!!ក៖ហ៊ឺៗ!!ខ៖ហើយក្នុងមួយខែគេផ្ញើរមកម្តង១០០០០០បាតអីអីចឹងទៅ។

ក៖ម៉េចទៅពូ១០០០០០ស្មើប៉ុន្មានលុយខ្មែរយើងហើយ?

ខ៖១០០០០០បាតបើគិតជាដុល្លារវិញ១០០០០០ស្មើ២៥០០ដុល្លារ។

ក៖ហូចំច្រើនអញ្ចឹង!!

ខ៖បាទអាហ្នឹងយើងគិត២នាក់ប្តីប្រពន្ធទេអាហ្នឹងអ្នកគ្រូហាំ!!

ក៖ចាំ!!អាហ្នឹងច្រើនតើពូ!!អីចឹងពូមូលហេតុអីបានលែងទៅធ្វើការនៅថៃហ្នឹង?

ខ៖វាអញ្ចេកខ្ញុំកាលញ៉ុមទៅហ្នឹងដោយសារញ៉ុមជំពាក់គេច្រើន!!ក៖ហ៊ឺៗ!!ខ៖ជំពាក់គេក៏ច្រើនហើយកូនក៏ឈឺហើយដល់ពេលហើយដីផ្ទះហ្នឹងរកតែរបូតទេអ្នកគ្រូញ៉ុមប្រាប់តាមត្រង់ហាំ!! ក៖ហ៊ឺ!!!ខ៖ជំពាក់គេដល់ថ្ងាក់គេមកទារព្រឹកល្ងាចដល់គេមកទារប្រពន្ធញ៉ុមដេរប្រចោរប្រពន្ធដល់រកលុយអត់ទាន់អើរភ័រគេចាំស្អែក (ពាក្យសំដីមិនល្អ)ម្តងថ្ងៃនេះម្តងថ្ងៃណោះប្រចោរប្រពន្ធញ៉ុមហា ដល់ញ៉ុមឈឺចាប់ញ៉ុមទៅហើយដល់តែញ៉ុមរួចជំពាក់គេហ្នឹងបានចិត្តញ៉ុមលែងចង់

ហើយណាមួយគេអោយញ៉ុមថែមបន្ត២ឆ្នាំទៀតដែរញ៉ុមអត់តបានថាញ៉ុមអត់តណាមួយយើងអាយុវាហួស ហើយគេយកត្រឹម៥៥ចុះហើយយើង៥០ជាងហើយ។

កៈហ៊ឺ!!តែពូនៅកំលាំងពេញ?

ខៈកំលាំងញ៉ុមនៅពេញហើយគ្រាន់ធ្វើការសំនង់ដូចអត់យ៉ាប់ដូចញ៉ុមនិយាយហើយដូចវាការងារក្រុមហ៊ុនហើយស៊ីម៉ង់អីលាយហ្នឹងអើរដូចថាចាក់បេតុងអីហ្នឹងឡានគេលាយចាក់មកបាញ់ចាក់ទាំងអស់។

កៈស្រួលហោពូ?

ខៈចាំគារចាំវា ចាំខាត់អោយស្មើទៅតែប៉ុណ្ណឹង។

កៈមិនមែនដូចយើងនៅណោះណាពូណោះ?

ខៈហើយសំភារៈដែលលើកឡើងញ៉ុមធ្វើហ្នឹង៧៧ជាន់ឡើងលើហ្នូ!!

កៈចំ!!

ខៈ៧៧ជាន់បើកំពស់គិតពីដីវិញ៣៥០កំពស់ពីដីទៅ។

កៈអីយ៉ា!!

ខៈបាទឡើងពីសុទ្ធតែជណ្ដើរយន្តជណ្ដើរអូតូម៉ូទិច។កៈចាំ!!ខៈហើយអីវ៉ាន់យកឡើងទៅលើតែត្រឹមតែ១០គីឡូ១៥គីឡូឡើងអត់មានយកកំលាំងយើងទេគឺគេស្ទូចយកអោយទៅដល់លើម៉ង!!

កៈហ្នឹងហើយ។ខៈបាទ!!កៈនិយាយទៅគេស្រលាញ់កំលាំងពលកម្មពូណាស់!!ខៈបាទ!!កៈមិនមែនដូចយើងនៅណោះប្រើអស់សាច់។

ខៈបាទហើយធ្វើការអោយតែជើងផុតពីដីអោយតែផុតពីកន្លះម៉ែត្រអោយយើងពាក់ខ្សែក្រវ៉ាត់ការពារខ្លាចគ្រោះថ្នាក់។

កៈចាំពិបាកដល់គេហាពូណាស់ !!ខៈបាទ!!កៈដោយសារគ្រោះថ្នាក់ទៅ។

ខ៖ហើយបើសិនណាយើងគ្រោះថ្នាក់ទៅបាត់បង់ជីវិត គេវាពិបាកដែរ គេបង់អោយយើង ២០០០០០បាតហា!!ក៖ហ៊ី១!!ខ៖យើងបាត់បង់ជីវិត!!ក៖ហ៊ី១!!ខ៖ដល់ពេលអ៊ិចឹងគេត្រូវការពារជីវិតអីទាំងអស់។ក៖ចា៎!!ខ៖ហើយក្រុមហ៊ុនទៅធ្វើថៃតែក្រុមហ៊ុនដែលកសាងនៅថៃហ្នឹង បាំងហ្នឹងពួកបាំងហ្នឹងកសាង។

ក៖ចា៎ហ្នឹងហើយ។ចា៎អ៊ីចឹងអរគុណច្រើនពូសំរាប់ការសំភាសន៍ដ៏ក្បោះក្បាយ!!ខ៖បាទ!!ក៖នៅក្នុងថ្ងៃនេះ!!ខ៖បាទ!!ក៖គឺល្អមែនទែនញ៉ុមរីករាយមែនទែនម៉ង!!

ខ៖ញ៉ុមជីវប្រវត្តិញ៉ុមបើនិយាយទៅអ្នកគ្រូបើថាសិនណាតែងជាកំណាព្យឬមួយក៏តែងជារឿងអីមួយ៣ខែទៀតក៏និយាយអត់អស់ដែរមែនតើ!!

ក៖ហ្នឹងហើយ អូ្វយពូមែនតើ!!ដល់ពេលនិយាយគ្នាធម្មតាទេដល់ពេលចាប់ផ្តើមយករឿងទាំងអស់ហ្នឹងមកគិតបានឆ្លងកាត់ថាជីវិតថាសាហាវមែន!!ខ៖បាទ!!ក៖អូ្វយ!!

ខ៖មុនហ្នំកាលញ៉ុមទៅដំបូងញ៉ុមទៅដំបូងទៅថៃដំបូងញ៉ុមទៅកោះសាម៉ុយហ្នំបានស្រងៃសស្រងោច។

ក៖ម៉េចទៅពូ!!

ខ៖កណ្តាលសមុទ្រ ។

ក៖ហើយកោះហ្នឹងអត់សូវធំប៉ុណ្ណឹងទេពូមែនទេ?

ខ៖អត់ធំម៉េចអើរបើគិតទៅកោះហ្នឹងបើគិតទៅខេត្តកណ្តាលយើងមួយអត់ប៉ុនផងហ្នឹងហេ!!

ក៖អូ្វយធំសាម៉ុយ??

ខ៖បាទ!!កោះសាម៉ុយនៅព្រំប្រទល់ជាប់ម៉ាឡេហ្នំ!!ក៖ហ្នំ!!ខ៖គិតទៅពីដីគោកមកទៅកណ្តាលកោះហ្នឹងកប៉ាល់វាដាក់ចំងាយល្បឿនវាគីឡូវា១៩០គីឡូវាខាត!!

ក៖អូ្វយឆ្ងាយណាស់អ៊ីចឹង!!

ខ៖១៩០គីឡូអ្នកគ្រូគិតមើលទៅ!!

ក៖ហើយជិះប៉ុន្មានម៉ោងបានមកដល់កោះពូ?

ខះគិតទៅវាចាប់ចេញពីនេះទៅម៉ោង៧ព្រឹក ម៉ោង៧ព្រឹកម៉ោង ម៉ោង១០កន្លះបានទៅដល់។

"កះអូ ៣ ៤ម៉ោងដែរអ៊ីចឹង??

ខះបាទ!!

កះអូយ!!ហើយម៉េចបានស្រងៃសស្រងោចអ៊ិចឹងពូ?

ខះស្រងៃសស្រងោចដល់ធ្វើ ដល់ធ្វើអញ្ចឹងវាអោយទៅធ្វើអាគារតែ៣ជាន់ធ្វើធ្វើនៅជាប់មាត់សមុទ្រអញ្ចេក។កះហ៊ឺៗ!!!ខះដល់តែធ្វើៗមើលអាក្រោមអាជាន់ក្រោមអត់សូវអីទេតែដល់អាឡើងដល់២ ជាន់៣ជាន់លើមើលទៅឃើញទឹកសមុទ្រល្វល្វេវ !!កះហ៊ឺៗ!!ខះមើលទៅឃើញទឹកសមុទ្រល្វល្វេវអញនៅអត់បាននឹកផ្ទះ ដល់ ដល់កន្លែងនឹកផ្ទះហើយណាស់!!កះចាំ!!ខះដល់នឹងផ្ទះអញ្ចឹងអាណាត្តិអត់ទាន់ផុតផងញ៉ុមបង់លុយផ្ដាច់នៅកោះសាម៉ុយញ៉ុមបង់ជាង១០០០០បាតហ្វាំបង់ជាង១០០០០បាតយកប៉ះស្ព័រមកវិញតើ !!កះហ៊ឺៗ!!ខះបើយើងអត់បង់លុយអោយវាទេយើងអត់បានប៉ះស្ព័រមកវិញអត់បាន ប៉ះស្ព័រគេដកទុក។កះចាំ!!ខះហើយដល់នេះហើយដល់បង់មកបានមកមកដល់ទីក្រុងថៃបមកដល់កណ្ដាលក្រុងមកដល់អស់លុយអាលីង!!កះចំ!!ខះអស់លុយអាលីងដល់មកដល់អស់លុយអាធានាអស់លុយមកចូលនៅអើរដល់នៅអើរកណ្ដាលទីក្រុងហើយទៅចូលធ្វើការធ្វើសំនង់នៅមួយខែទៅធ្វើនៅពួកអាការងារម៉ៅអាពួកឯកជនហ្នឹង ធ្វើបានមួយខែយកលុយមកផ្ទះ។

កះហើយពូចេះថៃទេទៅហ្នឹង?

ខះកាលទៅចេះខ្លះដែរតែឥឡូវភ្លេចអស់ហើយ ចាំតែមួយម៉ាត់ៗហ្នឹង!!

កះចាំហ្នឹងហើយ អញ្ចឹងបានត្រលប់មកផ្ទះរស់នៅជាមួយក្រុមគ្រួសារសុខសុភមង្គលដល់សព្វថ្ងៃ?ខះបាទ!!កះសព្វថ្ងៃហ្នឹងទៅ!!!

ខះបាទហើយកាលពេលមកដល់អ្នកគ្រូអើយ ដល់ឃើញអនិច្ចាកូនវាដូចថាម៉ែហើយមីបងទៅធ្វើរោងចក្រហើយនៅតែ៣នាក់ម៉ង់ៗ ជួនកាលគេថែមម៉ោងគេមានមកផ្ទះណា នៅដេក៣នាក់បងប្អូនផ្ទះអញ្ចឹងទៅ!!កះហ៊ឺៗ!!ខះហើយដល់ពេលយើងខ្វះខាតអ្នកគ្រូហើយគាត់ទុក ជួនកាលទុកលុយអោយសំរាប់ទិញម្ហូប១៥០០ព្រឹកល្ងាច៣នាក់បងប្អូន!!

កះងាប់ងាប់ម៉ង!!

ខ៖ហើយគិតមើលហើយលុយទៅរៀនជួនកាលមានទៅជួនកាលអត់ទៅជួនកាលនេះ ជួនកាល២០០ ៣០០អីហ្នឹងយ៉ាងច្រើនម្នាក់ៗហើយអញ្ចឹងដល់បែងចែកគ្រប់កន្លែងដល់មក ឃើញកូនក្បាលឡើងត្រមែងត្រមែងគ្រប់គ្នាដល់អញ្ចឹងញ៉ុមអនិច្ចាណាស់ អនិច្ចាបាន ហើយ ណាមួយញ៉ុមជំពាក់គេ!!អ៊ីចឹងទៅបានញ៉ុមដូចដកបន្លាចេញពីទ្រូង។

ក៖អ៊ីចឹងចប់ទៅហើយលែងទៅទៅពូណោះ??

ខ៖បាទ!!

ក៖ហ៊ុហ្នឹងហើយ ចាំអ៊ីចឹងអរគុណច្រើនណាស់លោកពូសំរាប់ការសំភាសន៍នៅក្នុងថ្ងៃនេះ!!

ខ៖បាទ!!

ក៖ឡូយមែនទែនអរគុណពូ។

ខ៖បាទអ៊ីចឹងបើសិនណានិយាយ៣ខែទៀតក៏វាមិនចប់ផង។

ក៖ចាំហ្នឹងហើយ អរគុណច្រើនលោកពូ៕